# របាយការណ៍

## ការផ្តល់អំណាចនយោបាយដល់ស្ត្រី
## និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
## អាណត្តិទី៥ ឆ្នាំ២០២២

**ខែធ្នូ ឆ្នាំ២០២២**

ខុមហ្វ្រែល COMFREL

SILAKA

GADC

បន្ទាយស្រី
BANTEAY SREI
Women Empowerment

អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
BUILDING COMMUNITY VOICES

# របាយការណ៍

## ការផ្តល់អំណាចនយោបាយដល់ស្ត្រី
## និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
## អាណត្តិទី៥ ឆ្នាំ២០២២



ប្រភព ៖ VOA Khmer

ខែធ្នូ ឆ្នាំ២០២២

# មាតិកា


បុព្វកថា......iii

ពាក្យអក្សរកាត់......v

I-**សេចក្តីផ្តើម** ......1

*ក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលមានសារៈសំខាន់សម្រាប់សមភាពយេនឌ័រនិងសិទ្ធិស្ត្រីនៅកម្ពុជា......1*

*ក្របខ័ណ្ឌច្បាប់ ......1*

*ក្របខ័ណ្ឌគោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសមភាពយេនឌ័រ......2*

II- ***ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២***......7

***១- ការជ្រើសរើសបេក្ខជនស្ត្រី និងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ***......7

*ក្រាហ្វិកទី១ ៖ ភាគរយបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ពីអាណត្តិទី១ ដល់ អាណត្តិទី៥ ......10*

*តារាងទី២ ៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ទាំង១៧គណបក្ស......11*

*ចំនួនបេក្ខជនស្ត្រីឈរឈ្មោះពីលេខរៀងទី១ ដល់ ទី៣ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២......13*

***២- ស្ត្រីជាប់ឆ្នោត***......16

*ក្រាហ្វិកទី៩ ៖ ភាគរយស្ត្រី-បុរសជាប់ឆ្នោត អាណត្តិទី៥ ឆ្នាំ២០២២......16*

*តារាងទី១១ ៖ ចំនួនស្ត្រី-បុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ តាមគណបក្ស......17*

*ការប្រៀបធៀបក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី-បុរសក្នុងការបោះឆ្នោតជ្រើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ និងអាណត្តិទី៥ ......18*

*រាជធានី ខេត្តដែលមានភាគរយស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងគេ......20*

*ក្រាហ្វិកទី១៤ ៖ ប្រៀបធៀបតួនាទីស្ត្រី និងបុរសជាប់ឆ្នោត អាណត្តិទី៥ ឆ្នាំ២០២២ ......21*

*ក្រាហ្វិកទី១៥ ៖ មេឃុំ ចៅសង្កាត់ស្ត្រីតាមវ័យ ថ្មី ចាស់ និងតាមតំបន់ អាណត្តិទី៥ ឆ្នាំ២០២២...22*

*ករណីសិក្សា ៖ ភាពលេចធ្លោរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២......23*

*ករណីសិក្សាទី១ ......23*

*ករណីសិក្សាទី២......26*

***៣- កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្ស អំពី បញ្ហាស្ត្រី និងកុមារ***......28

តារាងទី១៦ ៖ កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ ........ 28
តារាងទី១៧ ៖ កម្មវិធីនយោបាយរបស់គណបក្សតាមឃុំ សង្កាត់នីមួយៗ ដែលបានសន្យាដោយបេក្ខជនស្ត្រីដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ........ 30
**៤- សមាជិកស្ត្រីរបស់ គ.ជ.ប លធ.ខប គធ.ខប គឃ.សប មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត** ........ 33
ថ្នាក់ជាតិ........ 33
ថ្នាក់ក្រោមជាតិ........ 33
ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត........ 34
ក្រាហ្វិកទី១៥ ៖ តួនាទីរបស់ស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត........ 35
**៥- អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយជាស្ត្រី**........ 35
អ្នកសង្កេតការណ៍ជាតិជាស្ត្រី........ 35
អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី........ 37
ភ្ញៀវពិសេសជាស្ត្រី........ 37
ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី........ 37
**៦. អ្នកបោះឆ្នោតស្ត្រី**........ 37
**៦.១. ស្ត្រីក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២១**........ 37
ក. ស្ត្រីដែលបានពិនិត្យឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត........ 37
ខ. ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត........ 39
គ. ចំណាប់អារម្មណ៍ និងការយល់ឃើញផ្ទាល់របស់អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែល........ 40
**៦.២. ថ្ងៃបោះឆ្នោត**........ 41
III- **សេចក្តីសន្និដ្ឋាន និងសង្ខេប**........ 44
IV- **អនុសាសន៍**........ 47

## ឧបសម្ព័ន្ធ

# បុព្វកថា

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា « ខុមហ្វ្រែល (COMFREL)» អង្គការសីលការកម្ពុជា (SILAKA Cambodia) អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GADC) អង្គការបន្ទាយស្រី(Bantey Srei)ជាសមាជិកនៃ«ក្រុមស្ត្រីដើម្បីទាំងអស់គ្នា» ដែលធ្វើការរួមគ្នាដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការដឹកនាំទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានចំពោះការចូលរួមរបស់ស្ត្រីតាមបែបប្រជាធិបតេយ្យ តាមរយៈការអភិវឌ្ឍន៍សមត្ថភាពស្ត្រី ការតស៊ូមតិ និងបញ្ចុះបញ្ចូលថ្នាក់ដឹកនាំគណបក្សនយោបាយ និងរដ្ឋាភិបាលក្នុងការបង្កើតគោលនយោបាយ និងច្បាប់ដើម្បីបង្កើនចំនួនតំណាងស្ត្រីនយោបាយ និងមានសមភាពយេនឌ័រនៅគ្រប់លំដាប់ថ្នាក់ ។

របាយការណ៍ ស្តីពី *"ការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២"* គឺជាទំរង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់ស្ត្រីកម្ពុជាដែលបានចូលរួមក្នុងកិច្ចការនយោបាយ ជាពិសេសក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កន្លងទៅនេះ ។ របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្តល់អំណាចនយោបាយដល់ស្ត្រី និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ អំពីចំនួនបេក្ខជនស្ត្រី ស្ត្រីជាប់ឆ្នោត គោលនយោបាយរបស់គណបក្សក្នុងការលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ កម្មវិធីនយោបាយរបស់គណបក្សអំពីបញ្ហាស្ត្រី និងកុមារ ការប្រឈមរបស់ស្ត្រីទាំងអ្នកបោះឆ្នោតនិងបេក្ខជនចូលរួមក្នុងដំណើរការបោះឆ្នោត មតិស្ត្រីនៅក្នុងកិច្ចការបោះឆ្នោត និងសកម្មភាពនានាដែលទាក់ទងទៅនឹងការលើកស្ទួយស្ត្រីឱ្យចូលរួមក្នុងវិស័យនយោបាយជាដើម ។ ម្យ៉ាងទៀត របាយការណ៍នេះក៏ផ្តល់នូវលទ្ធផលនៃការសង្កេតឃ្លាំមើលការចូលរួមនយោបាយរបស់ស្ត្រីក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងលទ្ធផលនៃការស្ទង់មតិហ័សនៅតំបន់គោលដៅរបស់ខុមហ្វ្រែលបន្ទាប់ពីថ្ងៃបោះឆ្នោតទៅលើ«*ស្ត្រីដែលបានទៅបោះឆ្នោត ឬមានទឹកខ្មៅនៅម្រាមដៃ និងស្ត្រីដែលមិនបានទៅបោះឆ្នោត ឬមិនមានទឹកខ្មៅនៅម្រាមដៃ* » និង ករណីសិក្សាចំនួន២ ។ ជាចុងក្រោយ របាយការណ៍នេះមានអនុសាសន៍សំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌរ័ និងការផ្តល់អំណាចនយោបាយដល់ស្ត្រីនៅក្នុងប្រទេសកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា របាយការណ៍នេះជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេសគណបក្សនយោបាយ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ រាជរដ្ឋាភិបាល បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍន៍ និងអ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងតួនាទីសម្រេចចិត្ត ។

សូមថ្លែងអំណរគុណជាពិសេសចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដែលតំណាងដោយ **លោកស្រី សឺនកេត សិរីលក្ខណ៍** ដែលជាអ្នកសរសេររបាយការណ៍នេះ ។ លោកស្រីក៏ជាប្រធានកម្មវិធីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល និងជាអ្នកដឹកនាំក្រុមការងារ ដូចជា **កញ្ញា នុត ជិ** ជាមន្ត្រីផ្នែកអប់រំ និងយេនឌ័រនៃខុមហ្វ្រែល និង**កញ្ញា ប៊្លី និ** ជាបុគ្គលិកស្ម័គ្រចិត្តផ្នែកអប់រំ និងយេនឌ័រខុមហ្វ្រែល ដែលបានខិតខំអនុវត្តតាមផែនការសកម្មភាពដើម្បីប្រមូលទិន្នន័យ សរសេររបាយការណ៍សង្កេត រចនារបាយការណ៍នេះ ដោយមានការគាំទ្រពីលេខាធិការខេត្តខុមហ្វ្រែល និងអ្នកសង្កេតការណ៍ស្ត្រី-បុរសនៃខេត្តគោលដៅទាំង៧របស់ខុមហ្វ្រែល

(COMFREL) អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV) និងអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)។

សូមថ្លែងអំណរគុណចំពោះក្រុមការងារ ដូចជា អង្គការសីលការកម្ពុជា (SILAKA Cambodia) អង្គការ GADC អង្គការBCV និងអង្គការបន្ទាយស្រី (Bantey Srei)ដែលបានរួមសហការជាមួយខុមហ្វ្រែលលើកិច្ចការស្វែងរកការគាំទ្រមតិ និងការសង្កេត ឃ្លាំមើលការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងសូមអរគុណជាអនេកប្បការចំពោះ**លោកស្រី យាង សេងហ៊ន** តំណាងអង្គការដោយកូនៀ (Diakonia) **លោកស្រី អិត ពៅ** ជាទីប្រឹក្សានៃខុមហ្វ្រែល **លោកស្រី គ្រី ស៊ុយហៀង** នាយិកាប្រតិបត្តិនៃអង្គការនារីដើម្បីសន្តិភាព (WPM) **លោកស្រី អេង ចាន់ឌី** នាយិកាប្រតិបត្តិនៃអង្គការGADC **លោកស្រី សេង រាសី** នាយិកាប្រតិបត្តិនៃអង្គការសីលកាកម្ពុជា និង**លោក គឹម ឈន** នាយកប្រតិបត្តិនៃអង្គការខុមហ្វ្រែលដែលបានផ្ដល់មតិយោបល់ល្អៗ និងគាំទ្រធ្វើឱ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត ។ យើងខ្ញុំសូមអរគុណផងដែរចំពោះ **លោក អ៊ុន សំណាង** ដែលបានជួយបកប្រែរបាយការណ៍នេះពីភាសាខ្មែរ ទៅជា ភាសាអង់គ្លេសបានយ៉ាងល្អ ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២

**តំណាងក្រុមការងារស្ត្រីក្នុងវិស័យនយោបាយ**
**អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល**

**សឺនកេត សិរីលក្ខណ៍**

# ពាក្យអក្សរកាត់ ( ACRONYMS )

| | |
|---|---|
| BSDP | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ |
| CEC | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CIPDP | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា |
| CNP | គណបក្សសញ្ជាតិកម្ពុជា |
| CNLP | គណបក្សខ្មែរស្រឡាញ់ជាតិ |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ នៅកម្ពុជា |
| CRP | គណបក្សកែទម្រង់កម្ពុជា |
| CPP | គណបក្សប្រជាជនកម្ពុជា |
| CP | គណបក្សភ្លើងទៀន |
| CPWP | គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ |
| CSO | អង្គការសង្គមស៊ីវិល |
| CYP | គណបក្សយុវជនកម្ពុជា |
| ECP | គណបក្សឯកភាពជាតិខ្មែរ |
| FUNCINPEC/FCP | រណសិរ្សរួបរួមជាតិដើម្បីឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការកម្ពុជា (គណបក្សហ្វ៊ុនស៊ិនប៉ិច) |
| GADC | អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា |
| GDP | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន |
| KEDP | គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច |
| KNUP | គណបក្សខ្មែររួបរួមជាតិ |
| KUP | គណបក្សខ្មែរតែមួយ |
| KP | គណបក្សកម្ពុជានិយម |
| KWP | គណបក្សឆន្ទៈខ្មែរ |
| NEC | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល |
| PSO | មន្ត្រីការិយាល័យបោះឆ្នោត |
| PSC | គណៈកម្មការការិយាល័យបោះឆ្នោត |
| PEC | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |

| | |
|---|---|
| RKP | គណបក្សរស្មីខេមរា |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SILAKA | អង្គការសីលការកម្ពុជា |
| VOA | សំឡេងអាមេរិក |

# I. សេចក្តីផ្តើម

បទពិសោធន៍និងការស្រាវជ្រាវរបស់ iKnow Politics បានរកឃើញថា ភាពចំរុះនៃយេនឌ័រផ្តល់នូវលទ្ធផលល្អប្រសើរជាងមុននៅក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ ហើយតួនាទីរបស់ស្ត្រីក្នុងដំណើរការនយោបាយទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានធ្វើឲ្យលទ្ធផលក្នុងប្រទេសមានភាពប្រសើរឡើងកាន់តែខ្លាំងថែមទៀត ។ សិទ្ធិរបស់ស្ត្រីក្នុងការបញ្ចេញសំលេងស្មើគ្នា និងការចូលរួមក្នុងឆាកនយោបាយមានមូលដ្ឋានរឹងមាំនៃការប្តេជ្ញាចិត្តរបស់អន្តរជាតិ ពីអនុសញ្ញានៃការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ីុ-ដរ/CEDAW) ឆ្ពោះទៅកាន់វេទិកាក្រុងប៉េងកាំងដើម្បីសកម្មភាព (Beijing Platform for Action) គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (Millennium Develoment Goals) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals) ។ ប៉ុន្តែស្ត្រីនៅតែបន្តមានតំណាងតិចតួចនៅគ្រប់ផ្នែកនៃជីវិតនយោបាយ ដូចជា ស្ត្រីនៅក្នុងគណបក្សនយោបាយ ស្ត្រីក្នុងដំណើរការបង្កើតច្បាប់ ស្ត្រីជាបេក្ខជនឈរឈ្មោះបោះឆ្នោត និងតំណាងស្ត្រីជាប់ឆ្នោត ។ល។ និង ។ល។

## ក្របខ័ណ្ឌច្បាប់និងគោលនយោបាយដែលមានសារៈសំខាន់សម្រាប់សមភាពយេនឌ័រនិងសិទ្ធិស្ត្រីនៅកម្ពុជា[1]

### ក្របខ័ណ្ឌច្បាប់ *(Legal Framework)*

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ដែលបានអនុម័តក្នុងឆ្នាំ១៩៩៣ បានហាមឃាត់យ៉ាងច្បាស់នូវការរើសអើងប្រឆាំងនឹងស្ត្រីនៅក្នុងមាត្រា៤៥ ដែលបានចែងថា «គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីត្រូវហាមឃាត់ ។ ការកេងប្រវ័ញ្ចស្ត្រីក្នុងការងារត្រូវហាមឃាត់»។ មាត្រា៣៨ ដែលធានាថា «មិនត្រូវមានការរំលោភបំពានលើរាងកាយណាមួយឡើយ» និងមាត្រា៤៦ ដែលចែងថា «ការជួញដូរមនុស្ស ការកេងប្រវ័ញ្ច ពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រីត្រូវហាមឃាត់» ។ ឧបករណ៍ច្បាប់ដើម្បីការពារ និងលើកកម្ពស់សិទ្ធិស្ត្រីដែលត្រូវបានបង្កើតឡើង និងអនុម័តតាំងពីឆ្នាំ១៩៩៣ រួមមាន ៖ ច្បាប់ស្តីពីការងារ(ឆ្នាំ១៩៩៧) ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ឆ្នាំ២០០៥) និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ឆ្នាំ២០០៨) ។

បន្ថែមពីលើក្របខ័ណ្ឌច្បាប់ជាតិដើម្បីការពារ និងលើកកម្ពស់សិទ្ធិស្ត្រី ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាមួយចំនួន ។ ជាក់ស្តែង ក្នុងឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ហើយក៏បានចូលរួមអនុម័តលើវេទិកា Beijing Platform for Action (BPFA) នៅក្នុងសន្និសីទពិភពលោកលើកទីបួនស្តីពី ស្ត្រី (FWCW)ក្នុងឆ្នាំ១៩៩៥។ ក្នុងនាមជារដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ(UN) ប្រទេសកម្ពុជាត្រូវ

[1] Advance International Training Programme (ITP 307, Statistics Sweden/SIDA) 2020 on Gender Statistics: Cambodia Team Assignment

បានចងភ្ជាប់ជាមួយនឹងការសម្រេចចិត្តទាំងអស់របស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ជាពិសេស ការសម្រេចចិត្តទាក់ទងនឹងស្ត្រី សន្តិភាព និងសន្តិសុខ ។

## *ក្របខ័ណ្ឌគោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសមភាពយេនឌ័រ (Policy Framework and government commitment to gender equality)*

ពីរទសវត្សរ៍ចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់សមភាពយេនឌ័រជាអាទិភាពចម្បងក្នុងរបៀបវារៈអភិវឌ្ឍន៍របស់រដ្ឋាភិបាលដោយទទួលស្គាល់ថា ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារសង្គមមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច-សង្គម និងការពង្រឹងតួនាទីស្ត្រីនៅក្នុងសង្គមដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គម[2] ។ សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី និងក្មេងស្រី ត្រូវបានចាត់ទុកជាសកម្មភាពដាច់ដោយឡែកផង និងបញ្ជ្រាបក្នុងកម្មវិធី ឬគម្រោងនានាផង នៅក្នុងការអនុវត្តផែនការអាទិភាពថ្នាក់ជាតិ ជាពិសេសត្រូវបានយកចិត្តដាក់ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី១, ទី២, ទី៣ និងទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដែលគឺជាកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs), គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs), ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយដើម្បីជានាក្របខណ្ឌពី 20% ទៅ50% ក្នុងការជ្រើសរើសមន្ត្រីរាជការស្ត្រីថ្មី[3] និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW)។

ទន្ទឹមនឹងនេះ យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាច្រើនត្រូវបានបង្កើតឡើង និងបានអនុវត្តជាបន្តបន្ទាប់។ ទាំងនេះរួមមាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (CNCW), ក្រុមការងារបច្ចេកទេសយេនឌ័រ (TWG-G), ក្រុមការងារបញ្ជ្រាបយេនឌ័រ (GMAGs), គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (WCCC), គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (CCWC) ដើម្បីសម្របសម្រួល និងផ្តល់ជំបូន្មាន បច្ចេកទេសជាពិសេសដល់វិស័យ និងស្ថាប័នរបស់ខ្លួន និងចូលរួមសកម្មភាពលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី។

ក្នុងនាមជាយន្តការយេនឌ័រថ្នាក់ជាតិ ក្រសួងកិច្ចការនារីសម្របសម្រួលជាមួយភាគីពាក់ព័ន្ធទាំងអស់ បង្កើត និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិរយៈពេលប្រាំឆ្នាំ គឺ «នារីរតនៈ(Neary Ratanak-NR)» និង បច្ចុប្បន្នហៅថានារីរតនៈទី៥ (NR V) ពីឆ្នាំ២០១៩-ឆ្នាំ២០២៣ ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅគ្រប់វិស័យ និងគ្រប់កម្រិតក្នុងប្រទេសកម្ពុជា។ វិស័យយុទ្ធសាស្ត្រនៅក្នុងនារីរតនៈទី៥នេះរួមមាន *១)ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។ ២)ការលើកកម្ពស់ការអប់រំរបស់ស្ត្រី និងក្មេងស្រី ។ ៣)ការលើកកម្ពស់សុខភាពរបស់ស្ត្រី និងក្មេងស្រី ។ ៤)កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ។*

---

[2] Royal Government of Cambodia (2018) Rectangular Strategy Growth, Employment, Equity and Efficiency, Phase-IV

[3] Prime Minister’s speech in the national forum on women in public and political leadership in 2015, committed set in policy as special measures

*៥)ស្ត្រីក្នុងវិស័យសាធារណៈ នយោបាយ និងភាពជាអ្នកដឹកនាំ និង៦) ការបញ្រ្ជាបយេនឌ័រក្នុងកម្មវិធីប្រែប្រួលអាកាសធាតុ*[4] ។

លើសពីនេះ ក្រសួងកិច្ចការនារីបានដើរតួនាទីដឹកនាំក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពី «សមភាពយេនឌ័រ» ដោយមានការរួមចំណែកនូវធាតុចូលមួយចំនួនពីអង្គការសង្គមស៊ីវិល (CSO) វិស័យឯកជន និងអ្នកពាក់ព័ន្ធសំខាន់ៗ និងដោយផ្អែកតាមមេរៀន និងបទពិសោធនក្នុងការអនុវត្តគោលនយោបាយ កម្មវិធីនិងយុទ្ធសាស្រ្តជាតិសំខាន់ៗ និងប្រើប្រាស់របកគំហើញនៃការប៉ាន់ប្រមាណយេនឌ័រនៅកម្ពុជាឆ្នាំ២០១៩ (CGA) ។ គោលនយោបាយនេះផ្តល់នូវក្រុបខ័ណ្ឌគោលនយោបាយរយៈពេលវែងសម្រាប់ និងពង្រឹងបន្ថែមទៀតនូវគោលការណ៍សមភាពយេនឌ័រនៅក្នុងគោលនយោបាយជាតិ ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ និងផែនការយុទ្ធសាស្រ្តតាមវិស័យ ដើម្បីសម្រេចបានសមភាពយេនឌ័រដែលស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងគោលបំណង «មិនបោះបង់នរណាម្នាក់ឱ្យនៅឯកោ» និងគោលការណ៍របស់ CEDAW នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ និងដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយបរិយាប័ន និងសមធម៌សម្រាប់ការកសាងមូលដ្ឋានគ្រឹះដើម្បីសម្រេចបាននូវចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០៥០ ។

ទោះបីជាយ៉ាងណា ប្រទេសកម្ពុជាពុំទាន់មាន**គោលនយោបាយសមភាពយេនឌ័រ**ជាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សនយោបាយដែលជាវិធានការពិសេស និងខ្វះ**នូវមាត្រាមួយចំនួនដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនៃច្បាប់បោះឆ្នោត**ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្រ្តី-បុរសដែលមានភាពចម្រុះចូលរួមស្មើគ្នាលើតួនាទីសម្រេចចិត្តក្នុងវិស័យនយោបាយស្របតាមអនុសញ្ញាស៊ី-ដរ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព*(SDG)* ដែលកម្ពុជាបានទទួលយក ។ បន្ថែម លើនេះទៀត សកម្មជនគណបក្សនយោបាយជាស្រ្តី និងអ្នកនយោបាយស្រ្តីនៅតែប្រឈមនឹង**ការរើសអើង** និងអំពើ**ហិង្សាគ្រប់ទម្រង់**ដែលជាឧបសគ្គរាំងពួកគេក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ និងការទទួលបាននូវយុត្តិធម៌យេនឌ័រ និងផលប្រយោជន៍ពីការចូលរួមក្នុងវិស័យនយោបាយ ។ អនុសញ្ញាស៊ី-ដរ មាត្រា៣ចែងថា ៖ ***«ក្នុងគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមាន ការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយសមភាពជាមួយបុរស»*** ។

លទ្ធផលស្ទង់មតិ ស្តីពី «ការចូលរួមរបស់សកម្មជននយោបាយស្រ្តីនៅក្នុងវិស័យនយោបាយនៅកម្ពុជា» របស់ខុមហ្វ្រែល ឆ្នាំ២០២០ បានបង្ហាញឱ្យឃើញថា ៖ អ្នកនយោបាយស្រ្តីនៅតែប្រឈមច្រើនទម្រង់នៃការរើសអើង និងអំពើហិង្សាប្រឆាំងនឹងពួកគេក្នុងការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគេ ទោះបីជាសិទ្ធិនយោបាយ និងការចូលរួមរបស់ស្ត្រីត្រូវបានធានាយ៉ាងពេញលេញដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិ CEDAW ក៏ដោយ ។ អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងវិស័យនយោបាយ គឺជាបទពិសោធដែលស្ត្រីបានជួបប្រទះជារៀងរាល់ថ្ងៃសម្រាប់ស្ត្រីដែលមានបំណងចូលរួមក្នុងឆាកនយោបាយ និងជាអ្នកនយោបាយ ។ **៧១%** នៃអ្នកចូលរួមក្នុងការស្ទង់មតិបានជួបប្រទះនូវអំពើហិង្សាប្រឆាំងនឹងស្ត្រី ។ **៨២%**

---

[4] Royal Government of Cambodia (2019-2023) Neary Rattanak V, five year strategic plan for strengthening gender mainstreaming and women's empowerment

បានប្រឈមនឹងការគំរាមកំហែង ។ **៧០,៩%** ប្រឈមនឹងអំពើហិង្សាផ្លូវចិត្ត ។ **៣៤.៥%** បានទទួលរងនូវការរំលោភបំពានលើរាងកាយ និង **៩,១%** ទទួលរងការបៀតបៀនលើផ្លូវភេទ ។

ជាលទ្ធផល កម្ពុជានៅបន្តបញ្ហាវិសមភាពនៃតំណាង និងការអនុវត្តសិទ្ធិរវាងបុរស និងស្ត្រីនៅក្នុងវិស័យនយោបាយ ។ ជាក់ស្តែង ភាគរយសរុបនៃស្ត្រី និងបុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មានគម្លាតគ្នាឆ្ងាយ ដែលក្នុងនោះស្ត្រីជាប់ឆ្នោត **២២%** និងបុរសជាប់ឆ្នោត **៧៨%** ខណៈពេលដែលសិទ្ធិអំណាចផ្លូវការពេញលេញរបស់ស្ត្រីក្នុងការបំពេញតួនាទីរបស់ខ្លួននៅមានការប្រឈមនឹងការរើសអើង និងនៅមានកម្រិត ។ នេះយើងមិនទាន់ វិភាគទៅដល់ភាពចម្រុះ ផ្សេងទៀតរបស់ស្ត្រីដែលមានពិការភាព ជនជាតិដើមភាគតិច អ្នកស្រលាញ់ភេទដូចគ្នា ជាដើមផង ដោយសារ ភាពមិនគ្រប់ជ្រុងជ្រោយនៃទិន្នន័យ ។

កម្ពុជាបានអនុវត្តនយោបាយវិមជ្ឈការតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលគាំទ្រដោយច្បាប់ស្តីពី *«ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់»* និងច្បាប់ស្តីពី *"ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់»* សម្រាប់អនុវត្តប្រចាំថ្ងៃរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំង ១៦២១ឃុំ សង្កាត់(ឆ្នាំ២០០២-២០០៧) ។ ១៦៣៣ឃុំ សង្កាត់ (ឆ្នាំ២០១២-២០១៦) និង១៦៤៦ឃុំ សង្កាត់ ឆ្នាំ២០១៧ និង ១៦៤៦ ឃុំ សង្កាត់ (ឆ្នាំ២០១៧-២០២២) និង ១៦៥២ ឃុំ សង្កាត់ (ឆ្នាំ២០២២-២០២៧) ។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ឆ្នាំ២០០២ រហូតមកដល់អាណត្តិទី៣ ឆ្នាំ២០១២ ចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់មានការកើនឡើងជាបន្តបន្ទាប់ ។ ប៉ុន្តែចំនួនស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០១៧បែរជាមានការថយចុះ និងអាណត្តិទី៥ ឆ្នាំ២០២២នេះក៏មិនមានភាគរយកើនបើធៀបនឹងចុងអាណត្តិទី៤ ។ ផ្ទុយទៅវិញ ស្ត្រីបានចូលរួមក្នុងកិច្ចការនយោបាយ ការបោះឆ្នោតយ៉ាងសកម្មទាំងសម្លេងនិងសកម្មភាពពីមួយអាណត្តិទៅមួយអាណត្តិ ។ គណបក្សពីរដែលទទួលបានការគាំទ្រពីអ្នកបោះឆ្នោត និងទទួលបានអាសនៈច្រើនក្នុងអាណត្តិទី៥នេះ គឺ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សភ្លើងទៀន** ប៉ុន្តែអ្នកដឹកនាំគណបក្សទាំងពីរនេះនៅខ្វះការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួន និងគោលនយោបាយរួមទាំងថវិកាដែលបម្រុងទុកក្នុងការបង្កើនសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងតួនាទីសម្រេចចិត្ត ដោយបានដាក់បេក្ខជនស្ត្រីឈរឈ្មោះមានភាគរយ**<u>តិច</u>** ហើយបេក្ខជនស្ត្រីភាគច្រើនឈរឈ្មោះនៅលេខរៀង**<u>ខាងក្រោម</u>**នៅក្នុងបញ្ជីឈរឈ្មោះគណបក្សរបស់ខ្លួនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ ។

លទ្ធផលស្ទង់មតិ ស្តីពី «ការចូលរួមរបស់សកម្មជននយោបាយស្ត្រីនៅក្នុងវិស័យនយោបាយនៅកម្ពុជា» របស់ខុមហ្វ្រែល ឆ្នាំ២០២០ បានរកឃើញទៀតថា ៖ ទោះបីស្ថានភាពនយោបាយមានការផ្លាស់ប្តូរយ៉ាងខ្លាំងជាពិសេសក្នុងអំឡុងពេលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ រួមទាំងការរួមតូចនៃលំហរប្រជាធិបតេយ្យសម្រាប់ពលរដ្ឋ ការបិទប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ការធ្លាក់ចុះនៃការគោរពសិទ្ធិមនុស្ស និងការបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលនិងការរំលាយគណបក្សសង្គ្រោះជាតិ ជាពិសេសការបំភិតបំភ័យ និងការរឹតត្បិតលើអ្នកនយោបាយស្ត្រី និងផលប៉ះពាល់នៃជំងឺកូវីដ១៩ **<u>៨៥.៥%</u>**នៃអ្នកចូលរួមការសិក្សាបានឆ្លើយថា ពួកគេនៅតែមានចំណាប់អារម្មណ៍ និងចូលរួមក្នុងនយោបាយ/ការបោះឆ្នោត ក្នុង

រយៈពេល ២ឆ្នាំ ឬ ៣ឆ្នាំខាងមុខ (ឆ្នាំ២០២២ និងឆ្នាំ២០២៣)។ **១៤.៥%**នៃអ្នកចូលរួមការសិក្សាបានបញ្ជាក់ថា ពួកគេមិនប្រាកដថាតើពួកគេនឹងបន្តការចូលរួមនយោបាយរបស់ពួកគេឬយ៉ាងណាឡើយ ។ អ្នកនយោបាយជាស្ត្រីម្នាក់បានបញ្ជាក់ថា *«ខ្ញុំនៅតែចាប់អារម្មណ៍នឹងនយោបាយ ពីព្រោះខ្ញុំជឿជាក់ថា ការចូលរួមរបស់ខ្ញុំ ក៏ដូចជាការចូលរួមរបស់ស្ត្រីដ៏ទៃទៀតអាចធ្វើឱ្យឋានៈរបស់ស្ត្រីមានភាពល្អប្រសើរនៅក្នុងប្រទេសកម្ពុជាទាំងមូល ។ ទោះជាយ៉ាងណាក៏ដោយ ការគាបសង្កត់នយោបាយ និងអំពើហិង្សាជាប្រព័ន្ធមានសភាពធ្ងន់ធ្ងរណាស់សព្វថ្ងៃនេះ ។ ដូច្នេះ ខ្ញុំចាំបាច់ត្រូវវាយតម្លៃស្ថានភាពឡើងវិញ និងស្វែងរកការគាំទ្របន្ថែមទៀតដើម្បីបន្តការខិតខំប្រឹងប្រែងក្នុងនយោបាយរបស់ខ្ញុំនាពេលអនាគត ។»*

**បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតនៅតែមានចំនួនតិច បើទោះបីចំនួនស្ត្រីមានការកើនឡើងនៅអាណត្តិទី៥ ឆ្នាំ២០២២នេះក៏ដោយ** ។ ជាក់ស្តែង បេក្ខភាពស្ត្រីឈរឈ្មោះជាបេក្ខជនបោះឆ្នោតកើនឡើងគួរឱ្យកត់សម្គាល់ ដែលមានចំនួនសរុប **២៧.៨១៣នាក់** ស្មើនឹង **៣២,៣%** នៃបេក្ខជនស្ត្រី-បុរសសរុប **៨៦.០៩២នាក់** មកពី គណបក្សនយោបាយទាំង**១៧** គឺ កើនចំនួន **៥%** ធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មានចំនួនតែ **២៧,២%** ប៉ុណ្ណោះ ។ ចំណែកឯ បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១ មានចំនួន **៦៥៣នាក់ (១២%)** គឺកើន ចំនួន **៤,១%** ធៀបនឹងឆ្នាំ២០១៧មានចំនួន **៧,៩% (៤៨១នាក់)** ។[5] ទោះបីយ៉ាងណាភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរស មានគម្លាតគ្នាឆ្ងាយរវាងភេទ គឺបេក្ខជនស្ត្រី **៣២,៣%** ខណៈដែលបេក្ខជនបុរសមានដល់ទៅ **៦៧,៧%** ។ មានតែគណបក្សប្រជាជនកម្ពុជាដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេស **១.៦៥២** ឃុំ សង្កាត់ និងគណបក្សភ្លើងទៀនមានបេក្ខជនឈរឈ្មោះស្ទើរតែទូទាំងប្រទេស **១.៦២៣** ឃុំ សង្កាត់ ។ ប៉ុន្តែគណបក្សទាំងពីរនេះបានដាក់បេក្ខជនស្ត្រីមានភាគរយតិច ។

**ចំនួនស្ត្រី និងបុរសជាប់ឆ្នោត មានគម្លាតគ្នាឆ្ងាយរវាងភេទនៃការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ ។ ជាក់ស្តែង** ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ មានចំនួន **២.៥៦២នាក់** ស្មើនឹង **២២%** នៃចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុប **១១.៦២២នាក់** ក្នុងនោះមានគណបក្សនយោបាយចំនួន៩ដែលទទួលបានសម្លេងឆ្នោតគាំទ្រ និងមានអាសនៈនៅឃុំ សង្កាត់ ។ បើប្រៀបធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ ស្ត្រីជាប់ឆ្នោតមានភាគរយប្រហាក់ប្រហែលគ្នា គឺ **២១,៨% (២.៥២២នាក់)** ចុងអាណត្តិទី៤ និង **២២% (២.៥៦២នាក់)** អាណត្តិទី៥ ឆ្នាំ២០២២ ។ ភាគរយសរុបនៃស្ត្រី និងបុរសជាប់ឆ្នោតមានគម្លាតគ្នាឆ្ងាយរវាងភេទ គឺស្ត្រីជាប់ឆ្នោត **២២%** និងបុរសជាប់ឆ្នោត **៧៨%** ។ មេឃុំចៅ សង្កាត់ស្ត្រី **១០,៥%** និងមេឃុំ ចៅសង្កាត់បុរស **៨៩,៥% បើទោះបីមេឃុំ** ចៅសង្កាត់ស្ត្រី មានការកើនឡើង **៣២នាក់ (២%)** ក៏ដោយ ។[6]

---

[5] លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ប្រកាសដោយ គ.ជ.ប នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

[6] លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

ចំនួននេះបង្ហាញពីការមិនទាន់ឆ្លើយតបគ្រប់គ្រាន់នូវភាពជាតំណាងរបស់ស្ត្រី ដែលនាំឱ្យប៉ះពាល់ដល់ (១)ផែនការយុទ្ធសាស្ត្រជាតិ ក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលមិនអាចសម្រេចបាននូវគោលដៅសមភាពយេនឌ័រ (២)ប៉ះពាល់ដល់ស្ត្រីដែលកំពុង និងត្រៀមនឹងប្រឡូកនៅក្នុងឆាកនយោបាយរាប់ចាប់តាំងពីកម្រិតឃុំ សង្កាត់ បង្ករឱ្យមានការបាក់ទឹកចិត្ត ដោយសារចំនួនស្ត្រីដែលជាគំរូភាពនៅតែមានតិចតួច (៣)បញ្ហាបរិយាប័ន្នសង្គមរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋានមិនត្រូវបានគេយកចិត្តទុកដាក់ និងឆ្លើយតបដោយប្រសិទ្ធភាព ដោយសារសម្លេងស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនតិចនៅឡើយ ។

របាយការណ៍ខាងក្រោមនេះ គឺបានពីអ្នកសង្កេតការណ៍បោះឆ្នោតស្ត្រីខុមហ្វ្រែល សហការជាមួយអង្គការអភិវឌ្ឍន៍សម្លេងសហគមន៍(BCV) និងអ្នកសង្កេតការណ៍ស្ត្រី-បុរសនៃអង្គការយេនឌ័រ និងការអភិវឌ្ឍន៍ដើម្បីកម្ពុជា(GADC) ក្រុមការងារយេនឌ័រ/ស្ត្រីនៃអង្គការសង្គមស៊ីវិល និងប្រភពទិន្នន័យផ្សេងៗ។ របាយការណ៍នេះគឺផ្តោតទៅលើបញ្ហា ឬការប្រឈម ដំណោះស្រាយ ឬវិធានការទាក់ទងនឹងការជ្រើសរើសស្ត្រីឈរឈ្មោះជាបេក្ខជន ការចុះបញ្ជីបេក្ខជនស្ត្រី-បុរស កម្មវិធីនយោបាយរបស់គណបក្សទាក់ទងនឹងការដោះស្រាយបញ្ហាស្ត្រី និងកុមារ ស្ត្រីជាប់ឆ្នោត ស្ត្រីជាមន្ត្រីរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្ត្រីជាអ្នកសង្កេតការណ៍ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកបោះឆ្នោតជាស្ត្រី ។

## II. ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

ការចូលរួមនយោបាយរបស់ស្ត្រីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ ត្រូវបានរកឃើញថា នៅតែមានភាពប្រឈមច្រើនរាប់ចាប់ពីការទទួលបានឱកាសក្នុងការឈរឈ្មោះជាបេក្ខជន ការចូលរួមបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីជាប់ឆ្នោត ។ ជាពិសេស បានទទួលឱកាសតិចតួចឈរឈ្មោះនៅលេខរៀងទី១នៃបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ និងមានគម្លាតគ្នាខ្លាំងរវាងបេក្ខជនស្ត្រី និងបេក្ខជនបុរស ស្ត្រីជាប់ឆ្នោត និងបុរសជាប់ឆ្នោត ហើយគម្លាតគ្នាកាន់តែខ្លាំងរវាង មេឃុំ ចៅសង្កាត់ស្ត្រី និងមេឃុំ ចៅសង្កាត់បុរសដែលជាអ្នកដើរតួនាទីសំខាន់ជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ផង និងជាអ្នកដឹកនាំ ចាត់ចែងអភិវឌ្ឍន៍នៅទូទាំង ១៦៥២ ឃុំ សង្កាត់ផង ។

### ១- ការជ្រើសរើសបេក្ខជនស្ត្រី និងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ

គណបក្សនយោបាយទាំង១៧ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅតែបង្ហាញឱ្យឃើញថា ការងារលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមានកំរិតនៅឡើយ តាមរយៈលទ្ធផលនៃការឈរឈ្មោះជាបេក្ខជន ជាពិសេសការឈរឈ្មោះជាបេក្ខជនរបស់ស្ត្រីនៅលំដាប់លេខរៀងទី១ដែលមានឱកាសច្រើនក្នុងការក្លាយជាអ្នកដឹកនាំនៅតាមឃុំ សង្កាត់ (ជាមេឃុំ ចៅសង្កាត់) ។ ជាក់ស្តែង ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ **លេខរៀងទី១ មានគម្លាតគ្នាខ្លាំង គឺ** បេក្ខជនស្ត្រី មានតែ **១២%** ខណៈដែលបេក្ខជនបុរសមានច្រើនលើសលុប **៨៨%** ។

យោងតាមលទ្ធផលនៃសិក្ខាសាលា ស្តីពី «ការបង្កើនចំនួនអ្នកដឹកនាំស្ត្រីក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្តនៅកម្ពុជា» ដែលសហការរៀបចំដោយ អង្គការខុមហ្វ្រែល (COMFREL) អង្គការសីលការកម្ពុជា (SILAKA Cambodia) អង្គការយេនឌ័រនិងអភិវឌ្ឍដើម្បីកម្ពុជា (GADC) អង្គការបន្ទាយស្រី (Bantey Srei) និងគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គសន/CPWP) នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលសង្កេត តាមដានគណបក្សនយោបាយក្នុងការបង្កើនចំនួនបេក្ខជនស្ត្រីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២របស់អង្គការខុមហ្វ្រែលកាលពីដើមឆ្នាំ២០២២ បានរកឃើញថា ក្នុងចំណោមគណបក្សនយោបាយទាំង១៧ដែលបានសម្ភាសន៍ និងចូលរួមក្នុងសិក្ខាសាលា គណបក្សភាគច្រើនមានផែនការសកម្មភាព ឬ គោលនយោបាយរបស់គណបក្សដោយបានកំណត់ភាគរយបេក្ខជនស្ត្រី-បេក្ខជនបុរសជាក់លាក់ និងបានប្តេជ្ញាចិត្តក្នុងការបង្កើនចំនួនបេក្ខជនស្ត្រីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ដោយគណបក្សខ្លះ២០% ខ្លះ២៥% ខ្លះ៣០% ខ្លះ៤៥% ខ្លះ៥០% គណបក្សខ្លះទៀតពី៦០% ទៅ ៧០% និងគណបក្សខ្លះមិនបានកំណត់ចំនួនជាក់លាក់ទេ គឺការសម្រេចចិត្ត

ផ្អែកលើសមត្ថភាពជាអាទិភាព ។ ប៉ុន្តែ គណបក្សទាំងអស់ពុំទាន់មានគោលនយោបាយ**សមភាព និងសមធម៌**យេនឌ័រដាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សរបស់ខ្លួននៅឡើយ ហើយគ្រប់គណបក្សនៅតែដាក់លក្ខខណ្ឌផ្ដោតតែកត្តាសមត្ថភាព និងធនធាន ។ គណបក្សទាំងអស់នៅតែបន្តនិយាយថា ពិបាករកស្ត្រី ជាពិសេស ស្ត្រីវ័យក្មេងចូលជាសមាជិក និងជាបេក្ខជនឈរឈ្មោះដែលការនិយាយបែបនេះកើតឡើងតាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី១ ឆ្នាំ២០០២ ។ ការលើកឡើងរបស់គណបក្សបែបនេះគ្រាន់តែជាលេសតែប៉ុណ្ណោះ ខណៈដែលសមាជិកស្ត្រីជាច្រើនមាននៅក្នុងគណបក្ស ហើយស្ត្រីទាំងនោះបានទទួលការបណ្ដុះបណ្ដាលអភិវឌ្ឍន៍ចំណេះដឹង និងបង្ហឹកសកម្មភាពជាច្រើនពីក្រុមស្ត្រីនៃអង្គការសង្គមស៊ីវិល ប៉ុន្តែ ជាក់ស្ដែង ស្ត្រីទាំងនោះភាគច្រើនមិនបានទទួលឱកាសឈរឈ្មោះជាបេក្ខជននៅលេខរៀងខាងលើ គឺបានឈរឈ្មោះនៅលេខរៀងខាងក្រោមៗដែលមិនមានលទ្ធភាពជាប់ឆ្នោត និងស្ត្រីខ្លះទៀតត្រូវបានថ្នាក់ដឹកនាំគណបក្សមិនផ្ដល់ឱកាសឱ្យឈរឈ្មោះជាបេក្ខជនឡើយ ។

ជាលទ្ធផល មាន**១៤គណបក្ស (៨២,៣%)** ក្នុងចំណោម ១៧គណបក្ស បានដាក់បេក្ខជនស្ត្រីឈរឈ្មោះចន្លោះពី **៣០% ទៅ ៥៥%**នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សខ្លួនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ចំនួននេះមាន**ភាពប្រសើរ** បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មានតែ**៨គណបក្ស(៦៦,៦%)**ក្នុងចំណោម១២គណបក្សនយោបាយ ។ គួរកត់សម្គាល់ថា ដោយសារគណបក្សពីរដែលមានសក្ដានុពលជាងគេ គឺ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សភ្លើងទៀន** បានដាក់បេក្ខជនស្ត្រីតិច ជាមូលហេតុនាំឱ្យស្ត្រីជាប់ឆ្នោតមានចំនួន**តិច** និងមាន**គម្លាតឆ្ងាយ**រវាងតំណាងស្ត្រីជាប់ឆ្នោត និងតំណាងបុរសជាប់ឆ្នោត។ យោងតាមរបាយការណ៍សង្កេតរបស់ខុមហ្វ្រែល ស្ដីពី «ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២» បេក្ខជនស្ត្រី ចំនួន ១៧រូប មកពី៤គណបក្សនយោបាយដូចជា គណបក្សប្រជាជនកម្ពុជា គណបក្សភ្លើងទៀន គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សខ្មែររួបរួមជាតិបានប្រាប់អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលនៅតាមឃុំ សង្កាត់ឱ្យដឹងថា ជាគោលការណ៍របស់គណបក្សមិនមានតម្រូវការថវិកាក្នុងការតែងតាំងបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតឡើយ ។ ប៉ុន្តែបេក្ខជនទាំងនោះ ត្រូវចំណាយថវិកាផ្ទាល់ខ្លួនបន្តិចបន្តួច និងបេក្ខជនស្ត្រីខ្លះចំណាយថវិកាត្រឹមតែ១លានរៀលដោយផ្អែកលើការស្ម័គ្រចិត្តសម្រាប់ការធ្វើសកម្មភាពឃោសនារបស់ខ្លួននៅតាមឃុំ សង្កាត់ ។

មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងមុនការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ក្រុមការងារស្ត្រី/យេនឌ័រនៃអង្គការសង្គមស៊ីវិល រួមមាន អង្គការខុមហ្វ្រែល អង្គការសីលការកម្ពុជា (SILAKA Cambodia) អង្គការយេនឌ័រ និងអភិវឌ្ឍដើម្បីកម្ពុជា (GADC) អង្គការបន្ទាយស្រី (Bantey Srei) និងគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គសន/CPWP) បានសិក្សាលើច្បាប់បោះឆ្នោត និងបានផ្ដល់នូវអនុសាសន៍មួយចំនួនប្រយោជន៍មានច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រដែលជាវិធានការសមស្របក្នុងការធានាឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត តាមរយៈការស្នើវិសោធនកម្មច្បាប់បោះឆ្នោតលើមាត្រាមួយចំនួន ។ ការកំណត់វិធានការពិសេសនៅក្នុងច្បាប់បោះឆ្នោត ឬហៅថា **ច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ** ជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដែល

អាចលើកទឹកចិត្តគ្រប់គណបក្សនយោបាយដាក់បេក្ខភាពស្ត្រីក្នុងបញ្ជីបេក្ខជនរបស់គណបក្ស ។ វិសោធកម្មច្បាប់បោះឆ្នោតនេះ កែលម្អបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលតម្រូវឱ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបេក្ខជនបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ ។ ការស្នើធ្វើវិសោធនកម្មច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ជំពូកទី៦** ៖ ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **មាត្រា៣៩** ***«បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម»*** និង ច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ **ជំពូកទី៤ មាត្រា២៧ និងមាត្រា២៨** ***«បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលនីមួយៗត្រូវមានបេក្ខជនស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់លេខរៀងពីលើដល់ក្រោម»*** នៃបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ ។ ចំណែកឯការបង្កើត និងអនុវត្ត**គោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សនយោបាយ** គឺជាវិធានការបន្ទាន់មួយក្នុងការបង្កើនចំនួនបេក្ខជនស្ត្រី និងចំនួនស្ត្រីនៅក្នុងក្រុមប្រឹក្សាភិបាលផ្ទៃក្នុងគណបក្ស និងក្នុងរចនាសម្ព័ន្ធធ្វើសេចក្តីសម្រេចផ្សេងទៀតនៅក្នុងគណបក្ស ។ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវជានាដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបេក្ខជនបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោម ។ តាមការសិក្សាស្រាវជ្រាវពីប្រទេសចំនួន៥ដែលមានភាពជោគជ័យក្នុងការលើកកម្ពស់សមភាពយេនឌ័រ ដូចជា ប្រទេសស៊ុយអែត(Sweden) ប្រទេសរវ៉ាន់ដា(Rwanda) ប្រទេសអាយស្លែន(Iceland) ប្រទេសន័រវែសន៍ (Norway) និងប្រទេសកាណាដា(Canada) បានបង្ហាញពីបទពិសោធឱ្យឃើញថា ការធ្វើឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ត្រូវមាន ៖ រដ្ឋធម្មនុញ្ញឆ្លើយតបនឹងយេនឌ័រ ច្បាប់សមភាពយេនឌ័រ ច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ គោលនយោបាយ ផែនការសកម្មភាព និងកញ្ចប់ថវិកាឆ្លើយតបនឹងយេនឌ័រ គឺជាឧបករណ៍ដ៏សំខាន់ ។ បន្ថែមពីនេះ ការប្តេជ្ញាចិត្តរបស់អ្នកដឹកនាំនិងឆន្ទៈនយោបាយក្នុងការគាំទ្រ គឺជាកត្តាចាំបាច់ដែលជម្រុញឱ្យការងារនេះទទួលបានជោគជ័យ ។

ជាមួយគ្នានេះដែរ ក្រុមការងារស្ត្រី/យេនឌ័រនៃអង្គការសង្គមស៊ីវិល បានសហការរៀបចំសិក្ខាសាលាចំនួន ៣ ស្តីពី « ការបង្កើន ចំនួនអ្នកដឹកនាំស្ត្រីនៅក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្តនៅកម្ពុជា»ក្នុងនោះ សិក្ខាសាលាថ្នាក់ជាតិ ចំនួន ១ តាមរយៈអនឡាញ និងនៅនឹងកន្លែងផ្ទាល់ និងសិក្ខាសាលាតាមរយៈពីចម្ងាយ (អនឡាញ)ចំនួន២ នៅថ្នាក់ខេត្ត គឺ ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២១ ដែលមានអ្នកចូលរួមសរុបចំនួន ១៧៧ នាក់ (ស្ត្រី ៤៥,១%) មកពី ៩ គណបក្សនយោបាយ រួមមាន គណបក្សប្រជាជនកម្ពុជា គណបក្សកម្ពុជានិយម គណបក្សខ្មែរស្រឡាញ់ជាតិ គណបក្សហ៊ុនស៊ិនប៉ិច គណបក្សខ្មែររួបរួមជាតិ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សសញ្ញាតិកម្ពុជា និងគណបក្សឯកភាពជាតិខ្មែរ តំណាងក្រសួង/មន្ទីរកិច្ចការនារី តំណាងគ.ជ.ប ប្រធានលធ.ឧប

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាស្រុក/ក្រុង តំណាងទូតមួយចំនួន ម្ចាស់ជំនួយ អង្គការជាតិ យុវជន សហគមន៍ និងអ្នកសារព័ត៌មានមួយចំនួន ។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង៖

- ស្វែងយល់ពីគោលនយោបាយ ឬផែនការសកម្មភាពរបស់គណបក្សក្នុងការដាក់បេក្ខជនស្ត្រីឈរឈ្មោះ សម្រាប់ការបោះឆ្នោតឃុំ ឆ្នាំ២០២២ និងការបោះឆ្នោតជាតិ ឆ្នាំ២០២៣ និងចែករំលែកអំពីលទ្ធផលនៃការស្ទង់មតិ ស្តីពីការចូលរួមរបស់សកម្មជននយោបាយស្ត្រីក្នុងវិស័យនយោបាយ នៅកម្ពុជា ។
- ចែករំលែកពីការសិក្សាអំពីបទពិសោធជោគជ័យនិងគោលនយោបាយលើកកម្ពស់ការចូលរួមនយោបាយរបស់ស្ត្រី និងថ្នាក់សម្រេចចិត្តពីប្រទេសដទៃ និងចំណុចសំខាន់ៗក្នុងការបង្កើតគោលនយោបាយសមភាពយេនឌ័រក្នុងវិស័យនយោបាយនៅក្នុងគណបក្ស ។
- បង្ហាញពីលទ្ធផលនៃការសិក្សាលើច្បាប់បោះឆ្នោតនៅកម្ពុជាក្នុងការបង្កើនតំណាងស្ត្រីជាប់ឆ្នោត និងតួនាទីសម្រេចចិត្ត និងស្វែងរកការគាំទ្រការស្នើវិសោធនកម្មច្បាប់បោះឆ្នោតនេះ ។

លទ្ធផលនៃសិក្ខាសាលា អ្នកចូលរួមទាំងអស់រួមទាំងគណបក្សនយោបាយ មានគំនិតដូចគ្នាក្នុងការ ***អំពាវនាវឱ្យមានគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្ស ក៏ដូចជាការស្នើធ្វើវិសោធនកម្មច្បាប់បោះឆ្នោត*** ដើម្បីនាំមកនូវសមភាពយេនឌ័រពិតប្រាកដនៅកម្ពុជា ។ ប៉ុន្តែ លើកលែងគណបក្សខ្មែររួបរួមជាតិ-KNUP មិនគាំទ្រលើការស្នើធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ពីព្រោះយល់ថា វាមិនសូវមានប្រយោជន៍ ហើយធ្វើឱ្យខាតផលប្រយោជន៍ដល់គណបក្សតូចៗមួយចំនួននៅកម្ពុជា ដូចជាគណបក្សខ្មែររួបរួមជាតិជាដើម ប្រសិនបើមានការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ។ ប៉ុន្តែ អ្នកជំនាញផ្នែកយេនឌ័របានពន្យល់ថា ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដើម្បីឆ្លើយតបនឹងយេនឌ័រនេះ មានប្រយោជន៍យ៉ាងខ្លាំងក្នុងការផ្តល់ឱកាសដល់ស្ត្រី និងបុរសចូលរួមដោយស្មើភាពគ្នាក្នុងវិស័យនយោបាយ ជាពិសេសការឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោត និងធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជាផងដែរ ។

### ក្រាហ្វិកទី១ ៖ ភាគរយបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពី អាណត្តិទី១ ដល់ អាណត្តិទី៥




ប្រភព ៖ គ.ជ.ប

## តារាងទី២ ៖ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ទាំង១៧គណបក្ស

| ល.រ | គណបក្ស | បេក្ខជនឈរឈ្មោះពេញសិទ្ធិ | | | | | | ចំនួនឃុំ សង្កាត់ |
|---|---|---|---|---|---|---|---|---|
| | | បេក្ខជនសរុប (ស្រី-ប្រុស) | ស្ត្រី | | បុរស | | | |
| | | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | | |
| ១ | ប្រជាជនកម្ពុជា | ២៨.០០៨ | ៧.២៥៩ | ២៥,៩ | ២០.៧៤៩ | ៧៤,១ | | ១.៦៥២ |
| ២ | ភ្លើងទៀន | ២៣.៩៣៩ | ៥.៥៦៤ | ២៣,២ | ១៨.៣៧៥ | ៧៦,៨ | | ១.៦២៣ |
| ៣ | ហ្វ៊ុនស៊ិនប៉ិច | ៩.៩៥២ | ៣.៨៩៩ | ៣៩,២ | ៦.០៥៣ | ៦០,៨ | | ៦៨០ |
| ៤ | ខ្មែររួបរួមជាតិ | ៨.៨១៥ | ៤.០៤៧ | ៤៥,៩ | ៤.៧៦៨ | ៥៤,១ | | ៥៩៦ |
| ៥ | ខ្មែរស្រឡាញ់ជាតិ | ៥.០៥០ | ២.១២២ | ៤២ | ២.៩២៨ | ៥៨ | | ៣១៥ |
| ៦ | សញ្ញាតិកម្ពុជា | ៣.៩៥៦ | ២.១៨៥ | ៥៥,២ | ១.៧៧១ | ៤៤,៨ | | ២៤៥ |
| ៧ | យុវជនកម្ពុជា | ១.៨២៤ | ៨៥២ | ៤៦,៧ | ៩៧២ | ៥៣,៨ | | ១១៤ |
| ៨ | កែទម្រង់កម្ពុជា | ៩៧៨ | ៣៧៣ | ៣៨,១ | ៦០៥ | ៦១,៩ | | ៥៩ |
| ៩ | ឆន្ទៈខ្មែរ | ១.០៥០ | ៥២៩ | ៥០,៤ | ៥២១ | ៤៩,៦ | | ៥៨ |
| ១០ | កម្ពុជានិយម | ៦៥៨ | ២៤២ | ៣៦,៨ | ៤១៦ | ៦៣,២ | | ៣៨ |
| ១១ | ប្រជាធិបតេយ្យមូលដ្ឋាន | ៤៨១ | ១៥៣ | ៣១,៨ | ៣២៨ | ៦៨,២ | | ៣២ |
| ១២ | ខ្មែរតែមួយ | ៤៥៧ | ២៤៨ | ៥៤,៣ | ២០៩ | ៤៥,៧ | | ៣០ |
| ១៣ | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ៣៩២ | ១៨១ | ៤៦,២ | ២១១ | ៥៣,៨ | | ២៣ |
| ១៤ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ២០២ | ៤១ | ២០,៣ | ១៦១ | ៧៩,៧ | | ១៩ |
| ១៥ | ឯកភាពជាតិខ្មែរ | ១៧៨ | ៦៤ | ៣៦ | ១១៤ | ៦៤ | | ១៤ |
| ១៦ | រស្មីខេមរា | ៨៨ | ៣៤ | ៣៨,៦ | ៥៤ | ៦១,៤ | | ៦ |
| ១៧ | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ៦៤ | ២០ | ៣១,៣ | ៤៤ | ៦៨,៨ | | ៤ |
| សរុប | | ៨៦.០៩២ | ២៧.៨១៣ | ៣២,៣ | ៥៨.២៧៩ | ៦៧,៧ | | |

ប្រភព ៖ គ.ជ.ប

## ក្រាហ្វិកទី៣ ៖ បេក្ខជនស្ត្រី និងបុរសសរុប អាណត្តិទី៥ ឆ្នាំ២០២២




យោងតាម លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ គ.ជ.ប សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥នេះ មានបេក្ខជនស្រី-ប្រុសប្រកួតប្រជែងសរុបចំនួន **៨៦.០៩២នាក់** (បេក្ខជនពេញសិទ្ធិ) ក្នុងនោះបេក្ខជនស្ត្រីមានចំនួន **២៧.៨១៣នាក់ (៣២,៣%)** មកពីគណបក្សនយោបាយទាំង**១៧** គឺ កើនចំនួន **៥%** ធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មានចំនួន **២៧,២%** ។ ទោះបីយ៉ាងណា ចំនួន និងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសមានគម្លាតគ្នាឆ្ងាយរវាងភេទ គឺបេក្ខជនស្ត្រីមានចំនួន **២៧ ៨១៣នាក់** ស្មើនឹង **៣២,៣%** ខណៈដែលបេក្ខជនបុរសមានដល់ទៅ **៥៨ ២៧៩នាក់** ស្មើនឹង **៦៧,៧%** ។

មានតែ**គណបក្សប្រជាជនកម្ពុជា**ដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅទូទាំងប្រទេស **១.៦៥២** ឃុំ សង្កាត់ និង**គណបក្សភ្លើងទៀន** មានបេក្ខជនឈរឈ្មោះស្ទើរទូទាំងប្រទេស **១.៦២៣** ឃុំ សង្កាត់ ។ ប៉ុន្តែគណបក្សទាំងពីរនេះ បានដាក់បេក្ខជនស្ត្រីឈរឈ្មោះភាគរយតិចដែលសុទ្ធសឹងជាគណបក្សបានទទួលសម្លេងគាំទ្រច្រើនជាងគេ ។ ជាក់ស្តែង ភាគរយសរុបបេក្ខជនស្ត្រី និងបេក្ខជនបុរសនៃគណបក្សទាំងពីរមានគម្លាតគ្នាឆ្ងាយរវាងភេទ គឺ គណបក្សភ្លើងទៀនមានបេក្ខជនស្ត្រីចំនួន **២៣,២%** ខណៈដែល បេក្ខជនបុរសមានចំនួន **៧៦,៨%** ។ គណបក្សប្រជាជនកម្ពុជាមានបេក្ខជនស្ត្រីចំនួន **២៥,៩%** និងបេក្ខជនបុរសចំនួន **៧៤,១%** ។ ចំណែកឯ គណបក្សដែលពុំសូវមានការគាំទ្រពីអ្នកបោះឆ្នោត បានដាក់បេក្ខជនស្ត្រីឈរឈ្មោះច្រើនគួរឱ្យកោតសរសើរ ដូចជា គណបក្សសញ្ជាតិកម្ពុជាចំនួន**៥៥,២%** គណបក្សខ្មែរតែមួយចំនួន**៥៤,៣%** គណបក្សឆន្ទៈខ្មែរចំនួន**៥០,៤%** គណបក្សយុវជនកម្ពុជាចំនួន**៤៦,៧%** គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យចំនួន **៤៦,២%** គណបក្សខ្មែររួបរួមជាតិចំនួន**៤៥,៩%** គណបក្សខ្មែរស្រឡាញ់ជាតិចំនួន**៤២%** គណបក្សហ្វ៊ុនស៊ិនប៉ិចចំនួន**៣៩,២%** គណបក្សរស្មីខេមរាចំនួន**៣៨,៦%** គណបក្សកែទម្រង់កម្ពុជាចំនួន**៣៨,១%** គណបក្សកម្ពុជានិយមចំនួន**៣៦,៨%** គណបក្សឯកភាពជាតិខ្មែរចំនួន**៣៦%** និងគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចចំនួន**៣១,៣%**។

សម្រាប់អាណត្តិទី៥នេះ យើងកត់សម្គាល់ឃើញថា ភាគរយបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតមាន**ភាគរយប្រហាក់ប្រហែលគ្នាទូទាំង ២៥ រាជធានី ខេត្ត** ដែលមានចន្លោះពី **២៤,៤% រហូតដល់ ៣៨,៨%** ។ *(សូមមើលឧបសម្ព័ន្ធ ១ ស្តីពី ចំនួនបេក្ខជនស្ត្រីឈរឈ្មោះតាមរាជធានី ខេត្ត)*។

## ចំនួនបេក្ខជនស្ត្រីឈរឈ្មោះពីលេខរៀងទី១ ដល់ ទី៣ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

### តារាងទី៤ ៖ បេក្ខជនឈរឈ្មោះបោះឆ្នោតនៅលេខរៀងទី១ តាមគណបក្ស

| ល.រ | គណបក្សនយោបាយ | បេក្ខជនឈរឈ្មោះពេញសិទ្ធិ លេខរៀងទី១ | | | |
|---|---|---|---|---|---|
| | | ស្ត្រី | | បុរស | |
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ប្រជាជនកម្ពុជា | ១៧០ | ១០,៣ | ១.៤៨២ | ៨៩,៧ |
| ២ | ភ្លើងទៀន | ១៥៥ | ៩,៦ | ១.៤៦៨ | ៩០,៤ |
| ៣ | ហ៊្វុនស៊ិនប៉ិច | ៦៨ | ១០ | ៦១២ | ៩០ |
| ៤ | ខ្មែររួបរួមជាតិ | ១០៨ | ១៨,១ | ៤៨៨ | ៨១,៩ |
| ៥ | ខ្មែរស្រឡាញ់ជាតិ | ៤៣ | ១៣,៧ | ២៧២ | ៨៦,៣ |
| ៦ | សញ្ញាតិកម្ពុជា | ៦៩ | ២៨,២ | ១៧៦ | ៧១,៨ |
| ៧ | យុវជនកម្ពុជា | ១៤ | ១២,៣ | ១០០ | ៨៧,៧ |
| ៨ | កែទម្រង់កម្ពុជា | ៤ | ៦,៨ | ៥៥ | ៩៣,២ |
| ៩ | ឆន្ទៈខ្មែរ | ៧ | ១២,១ | ៥១ | ៨៧,៩ |
| ១០ | កម្ពុជានិយម | ៤ | ១០,៥ | ៣៤ | ៨៩,៥ |
| ១១ | ប្រជាធិបតេយ្យមូលដ្ឋាន | ២ | ៦,៣ | ៣០ | ៩៣,៨ |
| ១២ | ខ្មែរតែមួយ | ១ | ៣,៣ | ២៩ | ៩៦,៧ |
| ១៣ | សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ៣ | ១៣ | ២០ | ៨៧ |
| ១៤ | ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១ | ៥,៣ | ១៨ | ៩៤,៧ |
| ១៥ | ឯកភាពជាតិខ្មែរ | ៣ | ២១,៤ | ១១ | ៧៨,៦ |
| ១៦ | រស្មីខេមរា | ១ | ១៦,៧ | ៥ | ៨៣,៣ |
| ១៧ | ខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច | ០ | ០,០ | ៤ | ១០០ |
| **សរុប** | **១៧គណបក្ស** | **៦៥៣** | **១១,៩** | **៤.៨៥៥** | **៨៨,១** |

ប្រភព ៖គ.ជ.ប

## ក្រាហ្វិកទី៥




អាណត្តិទី៥ ឆ្នាំ២០២២នេះចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រីនិងបេក្ខជនបុរសឈរឈ្មោះនៅ**លេខរៀងទី១មានគម្លាតគ្នាខ្លាំង** **គឺ** បេក្ខជនស្ត្រីមានចំនួន **៦៥៣នាក់** **(១២%)** និងបេក្ខជនបុរសមានចំនួនច្រើនលើសលុប **៤ ៨៥៥នាក់** (៨៨%) ។ ទោះបីយ៉ាងណា បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី១សម្រាប់អាណត្តិទី៥នេះ បានកើន ៤,១% បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មាន **៧,៩%** ។

ប្រភព ៖ គ.ជ.ប

## ក្រាហ្វិកទី៦




ដូចគ្នាដែរ ចំនួន និងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ**លេខរៀងទី២ក៏មានគម្លាតគ្នាខ្លាំង** គឺ បេក្ខជនស្ត្រីមានចំនួន១០១៨នាក់ (១៨%)និងបេក្ខជនបុរសមានចំនួនច្រើនលើសលុប **៤ ៤៩០នាក់** (៨២%)។ គួរកត់សម្គាល់ថា បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី២សម្រាប់អាណត្តិទី៥នេះ បានកើន៣,៣% បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧មាន១៤,៧%។

## ក្រាហ្វិកទី៧




ប្រភព ៖ គ.ជ.ប

ចំនួន និងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ**លេខរៀងទី៣** **ក៏មានគម្លាតគ្នាខ្លាំង** គឺ បេក្ខជនស្ត្រីមានចំនួន**១៣៩៣នាក់** **(២៥%)**និង**បេក្ខជនបុរសមានចំនួន** **៤ ១១៥នាក់** **(៧៥%)** នៃចំនួនសរុប ស្រី-ប្រុស ៥ ៥០៨នាក់ ។ ដូចគ្នាដែរ បេក្ខជនស្ត្រីឈរឈ្មោះនៅលេខរៀងទី៣សម្រាប់អាណត្តិទី៥នេះបាន កើនតិចតួច **២,៧%** បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មាន ២២,៣%

ក្រាហ្វិកទី៨




ប្រភព ៖ គ.ជ.ប

ដោយឡែក ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រីនិងបេក្ខជនបុរសឈរឈ្មោះ **ពីលេខ រៀងទី១ ដល់ទី៣ ក៏មានគម្លាតគ្នាខ្លាំងដែរ** គឺ បេក្ខជនស្ត្រីមានចំនួន **៣ ០៦៤នាក់ (១៨,៥%)** ខណៈដែលបេក្ខជនបុរសមានចំនួន **១ ៣៤៦០ នាក់** (៨១,៥%)នៃចំនួនសរុបស្រី-ប្រុស ១៦ ៥២៤នាក់ ។ ភាគរយបេក្ខជនស្ត្រីឈរឈ្មោះពីលេខរៀងទី១ ដល់ ទី៣ នេះបានកើនតិចតួច **៣,៥%** បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មាន ១៥% ។

តួលេខទាំងនេះបង្ហាញឱ្យឃើញថា កម្ពុជានៅតែបន្តបញ្ហាអតុល្យភាពនៃការអនុវត្តសិទ្ធិ និងអំណាចនយោបាយរវាងស្ត្រីនិងបុរស បើទោះបីកម្ពុជាទទួលយកនូវវិធានការពិសេសដូចជា អនុសញ្ញាអន្តរជាតិស៊ីដ-គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងមានផែនការអភិវឌ្ឍជាតិដើម្បីលើកកម្ពស់ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមសកម្ម និងស្មើភាពរវាងស្ត្រី-បុរសទាំងបរិមាណ និងសិទ្ធិអំណាចក៏ដោយ ។

យោងតាមរបាយការណ៍សង្កេតរបស់ខុមហ្វ្រែល ស្តីពី«ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២» ស្ត្រីនៅតែមានបញ្ហាប្រឈមក្នុងការភ្ជាប់ខ្លួនជាមួយនឹងកិច្ចការនយោបាយ និងការបោះឆ្នោត ។ ពួកគេមានបញ្ហាប្រឈមចម្បងៗចំនួនបួន ៖ ***ទី១ ៖*** ពុំទាន់មាន**គោលនយោបាយសមភាពយេនឌ័រ**ដាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សនយោបាយ ដែលជាវិធានការពិសេស និងខ្វះនូវមាត្រាមួយចំនួននៃច្បាប់បោះឆ្នោត ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រី-បុរសចូលរួមស្មើគ្នាក្នុងវិស័យនយោបាយ ជាពិសេសការឈរឈ្មោះ ជាបេក្ខជន និងបានជាប់ឆ្នោត ។ ***ទី២ ៖*** បន្តការរើសអើងប្រឆាំងនឹងស្ត្រីបានកើតឡើងភាគច្រើនក្នុងដំណើរការបោះឆ្នោតជ្រើសរើសបេក្ខជន និងការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្សនយោបាយ និងការប្រឈមនឹងអំពើហិង្សាជាច្រើនទម្រង់។ ***ទី៣ ៖*** កង្វះឆន្ទៈនយោបាយរបស់គណបក្ស និងការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំក្នុងការជម្រុញឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ។ ***ទី៤ ៖*** បទដ្ឋានវប្បធម៌ និងសង្គមមួយចំនួនដែលមានផ្នត់គំនិតអវិជ្ជមានក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺជាឫសគល់បញ្ហាបង្កជារនាំងរាំងដល់ការចូលរួមរបស់អ្នកនយោបាយស្ត្រីប្រកបដោយគុណភាពនិងប្រសិទ្ធភាព ។

## ២- ស្ត្រីជាប់ឆ្នោត

### ក្រាហ្វិកទី៩ ៖ ភាគរយស្ត្រី-បុរសជាប់ឆ្នោត អាណត្តិទី៥ ឆ្នាំ២០២២




ប្រភព ៖ គ.ជ.ប

**ភាគរយសរុបនៃស្ត្រីជាប់ឆ្នោត និងបុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ មានគម្លាត គ្នាខ្លាំងរវាងភេទ** គឺ ស្ត្រីជាប់ឆ្នោតមានចំនួន **២២%** ស្មើនឹង **២.៥៦២**នាក់ និងបុរសជាប់ឆ្នោតមានចំនួន ច្រើនលើសលុប **៧៨%** ស្មើនឹង **៩.០៦០នាក់** នៃចំនួន ក្រុមប្រឹក្សាឃុំ សង្កាត់ស្រី-ប្រុស សរុប ១១.៦២២នាក់។

តួលេខនេះបង្ហាញថា វិសមភាពយេនឌ័រក្នុងវិស័យនយោបាយនៅតែជាបញ្ហាត្រូវការចាំបាច់បន្ថែមការ យកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធក្នុងការលើកស្ទួយការចូលរួមដោយស្មើភាពរវាងស្ត្រី និងបុរស តាមរយៈ បង្កើត និងអនុវត្តវិធានការពិសេសនានា។

### ក្រាហ្វិកទី១០




មាន**គម្លាតគ្នាខ្លាំង**រវាងស្ត្រីជាប់ឆ្នោត និងបុរស ជាប់ឆ្នោតជាមេឃុំ ចៅសង្កាត់ សម្រាប់អាណត្តិទី៥ ឆ្នាំ២០២២ ដែលមានមេឃុំ ចៅសង្កាត់**ស្ត្រី ១០,៥%** និងមេឃុំ ចៅ សង្កាត់**បុរស ៨៩,៥%** បើទោះបីមេឃុំចៅ សង្កាត់ស្ត្រីមានការកើនឡើងបន្តិច **២%** ក៏ដោយ។ ស្ថិតិ នេះ បង្ហាញពីភាពមិនមានសមាមាត្រគ្នាយ៉ាងខ្លាំងរវាង ចំនួនស្ត្រី និងបុរសជាប់ឆ្នោតដែលជាការឆ្លុះបញ្ចាំងពី កង្វះការលើកកម្ពស់ការចូលរួមរបស់ស្ត្រីដោយស្មើភាព គ្នាក្នុងនយោបាយ និងថ្នាក់សម្រេចចិត្ត ។

ប្រភព ៖ គ.ជ.ប

## ✚ តារាងទី១១ ៖ ចំនួនស្ត្រី-បុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ តាមគណបក្ស

| គណបក្សនយោបាយ | អាសនៈទទួលបានសរុប | ស្ត្រី | | បុរស | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រជាជនកម្ពុជា | ៩ ៣៧៦ | ២ ៣៦២ | ២៥,២ | ៧ ០១៤ | ៧៤,៨ |
| ភ្លើងទៀន | ២ ១៩៨ | ១៩៩ | ៩ | ១ ៩៩៩ | ៩១ |
| ហ៊ុនស៊ិនប៉ិច | ១៩ | ០ | ០ | ១៩ | ១០០ |
| ខ្មែររួបរួមជាតិ | ១៣ | ០ | ០ | ១៣ | ១០០ |
| ប្រជាធិបតេយ្យមូលដ្ឋាន | ៦ | ១ | ១៦,៧ | ៥ | ៨៣,៣ |
| ខ្មែរស្រលាញ់ជាតិ | ៥ | ០ | ០ | ៥ | ១០០ |
| យុវជនកម្ពុជា | ៣ | ០ | ០ | ៣ | ១០០ |
| កម្ពុជានិយម | ១ | ០ | ០ | ១ | ១០០ |
| សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ១ | ០ | ០ | ១ | ១០០ |
| **សរុប** | ១១ ៦២២ | ២ ៥៦២ | ២២ | ៩ ០៦០ | ៧៨ |

ប្រភព ៖ គ.ជ.ប

ដូចគ្នាផងដែរ ចំនួននិងភាគរយសរុបនៃស្ត្រីជាប់ឆ្នោត និងបុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ **អាណត្តិទី៥នៃគណបក្សនយោបាយទាំងបី មានគម្លាតគ្នាខ្លាំងរវាងភេទ** គឺ គណបក្សប្រជាជនកម្ពុជា មានស្ត្រីជាប់ឆ្នោតចំនួន **២ ៣៦២នាក់ (២៥,២%)** និងបុរសជាប់ឆ្នោតចំនួន **៧ ០១៤នាក់ (៧៤,៨%)** ខណៈដែល គណបក្សភ្លើងទៀន មានស្ត្រីជាប់ឆ្នោត **១៩៩នាក់ (៩%)** និងបុរសជាប់ឆ្នោតដ៏ច្រើនលើសលុប **ចំនួន ១ ៩៩៩នាក់ (៩១%)** ។ ចំណែកឯ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន មានស្ត្រីជាប់ឆ្នោតចំនួន **១នាក់ (១៦,៧%)** ខណៈដែលបុរសជាប់ឆ្នោតចំនួន **៥នាក់ (៨៣,៣%)** ។

## ការប្រៀបធៀបក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី-បុរសក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ និងអាណត្តិទី៥

### ក្រាហ្វិកទី១២




ប្រភព ៖ គ.ជ.ប

បើប្រៀបធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ ស្ត្រីជាប់ឆ្នោតមានភាគរយប្រហាក់ប្រហែលគ្នា គឺ ២១,៨% (២ ៥២២នាក់) ចុងអាណត្តិទី៤ និង ២២% (២ ៥៦២នាក់) អាណត្តិទី៥ ឆ្នាំ២០២២[7] ។ ខណៈដែលស្ត្រីនិងបុរសជាប់ឆ្នោតទាំងពីរអាណត្តិនេះ (អាណត្តទី៤ និងអាណត្តិទី៥) មានគម្លាតគ្នាឆ្ងាយរវាងភេទ ។

[7] លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

## ក្រាហ្វិកទី១៣

### លទ្ធផលតាមគណបក្ស៖

### គណបក្សប្រជាជនកម្ពុជា

ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី-បុរស
(លទ្ធផលបឋម) អាណត្តិទី៤ ឆ្នាំ២០១៧




ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី-បុរស
អាណត្តិទី៥ ឆ្នាំ២០២២




### គណបក្សភ្លើងទៀន

ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី-បុរស
អាណត្តិទី៥ ឆ្នាំ២០២២




ប្រភព ៖ គ.ជ.ប

គណបក្សពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សភ្លើងទៀន ទទួលបានសម្លេងឆ្នោតគាំទ្រច្រើនពីអ្នកបោះឆ្នោត និងមានស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សា ឃុំ សង្កាត់ ។ គណបក្សប្រជាជនកម្ពុជា មានស្ត្រីចំនួន

**២ ៣៦២នាក់ (២៥,២%)** ក្នុងនោះមេឃុំ ចៅសង្កាត់ស្ត្រីមានចំនួន**១៧៣នាក់ (១០,៥%)** ខណៈដែលគណបក្សភ្លើងទៀន មានស្ត្រីចំនួន **១៩៩នាក់ (៩%)** និងពុំមានស្ត្រីជាមេឃុំ ចៅសង្កាត់ឡើយ ។

ចំនួននេះបង្ហាញពីការមិនទាន់ឆ្លើយតបគ្រប់គ្រាន់នូវភាពជាតំណាងរបស់ស្ត្រី ដែលនាំឱ្យប៉ះពាល់ដល់ (១)ផែនការយុទ្ធសាស្ត្រជាតិ ក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលមិនអាចសម្រេចបាននូវគោលដៅសមភាពយេនឌ័រ (២)ប៉ះពាល់ដល់ស្ត្រីដែលកំពុង និងត្រៀមនឹងប្រឡូកនៅក្នុងឆាកនយោបាយរាប់ចាប់តាំងពីកម្រិតឃុំ សង្កាត់ បង្ករឱ្យមានការបាក់ទឹកចិត្ត ដោយសារចំនួនស្ត្រីដែលជាគំរូភាពនៅតែមានតិចតួច (៣)បញ្ហាបរិយាប័នសង្គមរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារនៅថ្នាក់មូលដ្ឋានមិនត្រូវបានគេយកចិត្តទុកដាក់ និងឆ្លើយតបដោយប្រសិទ្ធភាព ដោយសារសម្លេងស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនតិចនៅឡើយ ។

ដោយឡែក ឃុំ សង្កាត់ដែល**គ្មានស្ត្រី**ជាប់ឆ្នោតជាក្រុមប្រឹក្សា អាណត្តិទី៥នេះ មានចំនួន **១២៦ឃុំ សង្កាត់** ក្នុងស្រុក ខណ្ឌចំនួន**៦៥** ក្នុង **២០ រាជធានី ខេត្ត** ។ រាជធានី ខេត្តដែល**មិនមានតំណាងស្ត្រី**ជាក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងគេ គឺ ៖ **ខេត្តកំពង់ចាមនិងខេត្តព្រៃវែង**ចំនួន១៤,៣% **ខេត្តកំពតចំនួន**១០,៣% **ខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ**ចំនួន៦,៣% និង**ខេត្តកំពង់ធំ**ចំនួន៥,៥% ។
*(ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ ៣)*

## *រាជធានី ខេត្តដែលមានភាគរយស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ច្រើនជាងគេ*




ប្រភព ៖ គ.ជ.ប

រាជធានី ខេត្តដែលមាន**ភាគរយស្ត្រីជាប់ឆ្នោតច្រើនជាងគេ** ដូចជា ខេត្តប៉ៃលិនចំនួន**៣០,៨%** ខេត្តឧត្តរមានជ័យចំនួន**២៩,៦%** ខេត្តកោះកុងចំនួន**២៨,១%** រាជធានីភ្នំពេញចំនួន**២៧,១%** ខេត្តសៀមរាប និងខេត្តបាត់ដំបងចំនួន**២៦%** ខេត្តស្វាយរៀងចំនួន**២៥,៧%** ខេត្តពោធិ៍សាត់ចំនួន**២៥,៥%** ខេត្តមណ្ឌលគិរីចំនួន**២៥,២%** ខេត្តក្រចេះចំនួន**២៤%** ខេត្តកំពង់ឆ្នាំងនិងខេត្តស្ទឹងត្រែងចំនួន**២៣,៩%** និងខេត្តព្រះវិហារចំនួន**២៣,៤%** ។ (*សូមមើលឧបសម្ព័ន្ធ២ ស្តីពី ចំនួនស្ត្រីជាប់ឆ្នោតតាមរាជធានី-ខេត្ត*)

### ក្រាហ្វិកទី១៤ ៖ ប្រៀបធៀបតួនាទីស្ត្រី និងបុរសជាប់ឆ្នោត អាណត្តិទី៥ ឆ្នាំ២០២២




ប្រភព ៖ គ.ជ.ប

មេឃុំ ចៅសង្កាត់ស្ត្រីសរុបមានចំនួន**១៧៣នាក់ (១០,៥%)** នៅក្នុងអាណត្តិទី៥ ឆ្នាំ២០២២ គឺកើនឡើងចំនួន**៣២នាក់ (២%)** បើប្រៀបធៀបនឹងចុងអាណត្តិទី៤ មានចំនួន ១៤១នាក់ (៨,៥%)។ ប៉ុន្តែចំនួននិងភាគរយមេឃុំ ចៅសង្កាត់ស្ត្រី និងបុរស មានវិសមភាពខ្លាំង គឺ ស្ត្រី ១៧៣នាក់ (១០,៥%) ខណៈដែលមេឃុំ ចៅសង្កាត់បុរសមានចំនួនច្រើនលើសលុប **១ ៤៧៩នាក់ (៨៩,៥%)** ក្នុងអាណត្តិទី៥នេះ ។

ចំនួននិងភាគរយសរុបស្ត្រី និងបុរសជាជំទប់ទី១/ចៅសង្កាត់រងទី១ ក៏មានគម្លាតគ្នាខ្លាំង គឺ ស្ត្រីមានចំនួន **៣២០នាក់ (១៩,៤%)** និងបុរសមានចំនួន **១ ៣៣២នាក់(៨០,៦%)** ។ ទោះបីយ៉ាងណា ភាគរយស្ត្រីជាជំទប់ទី១/ចៅសង្កាត់រងទី១ បានកើន ៥,២% បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មាន ១៤,២% ។ ស្ត្រីជា

ជំទប់ទី២/ចៅសង្កាត់រងទី២ មានចំនួនតិចតួច **១៨៩នាក់ (១១,៤%)** ខណៈដែល បុរសមានចំនួនច្រើនលើសលុប **១ ៤៦៣នាក់ (៨៨,៦%)** ។ រីឯ ស្ត្រីជាសមាជិក មានចំនួន **១ ៨៨០នាក់ (២៨,២%)** និងបុរសមានចំនួន **៤ ៧៨៦នាក់ (៧១,៨%)** ។

## ក្រាហ្វិកទី១៥ ៖ មេឃុំ ចៅសង្កាត់ស្ត្រីតាមវ័យ ថ្មី ចាស់ និងតាមតំបន់ អាណត្តិទី៥ ឆ្នាំ២០២២




ប្រភព ៖ គជប

ក្រាហ្វិកទី១៥នេះ បង្ហាញឱ្យឃើញថា ក្នុងចំណោមមេឃុំ ចៅសង្កាត់ស្ត្រីសរុប ១៧៣នាក់ មាន**ស្ត្រីវ័យចំណាស់ចំនួន ១៤០នាក់** (៨១%) និង**ស្ត្រីវ័យក្មេងចំនួន ៣៣នាក់** (១៩%) ក្នុងនោះ មេឃុំស្ត្រីនៅ**តំបន់ដាច់ស្រយាលមានចំនួន ៥នាក់** (៣%) និងមេឃុំស្ត្រី**ជាជនជាតិដើមភាគតិចមានចំនួន** ៣នាក់ (២%) ។

ក្នុងចំណោមមេឃុំ ចៅសង្កាត់ស្ត្រីសរុប **១៧៣នាក់ ស្ត្រីមេឃុំ ចៅសង្កាត់ថ្មី**ជាស្ត្រីដែលទើបតែបានជាប់ឆ្នោតតួនាទីជាមេឃុំ ចៅសង្កាត់លើកដំបូង មានចំនួន**ច្រើនលើសលុប ១១២នាក់ ស្មើនឹង ៦៥%** (*ស្ត្រីវ័យក្មេងចំនួន ៣០នាក់ ស្មើនឹង ២៧% និងស្ត្រីវ័យចំណាស់មានចំនួន ៨២នាក់ ស្មើនឹង ៧៣%*)

ខណៈដែលស្ត្រីមេឃុំ ចៅសង្កាត់**ចាស់** (ស្ត្រីដែលធ្លាប់បានតួនាទីជាមេឃុំ ចៅ សង្កាត់តាំងពីអាណត្តិមុនៗ) មានចំនួនតែ **៦១នាក់ ស្មើនឹង ៣៥%** ប៉ុណ្ណោះ ។ តួលេខនេះបញ្ជាក់ថា ស្ត្រីបានទទួលឱកាសជាអ្នកដឹកនាំនៅថ្នាក់មូលដ្ឋានកាន់តែច្រើនជាងមុន និងបានចាប់យកបទពិសោធនៃការដឹកនាំនៅក្នុងជីវិតនយោបាយរបស់ខ្លួន ។ (*សូមមើលឧបសម្ព័ន្ធ ៤ ស្តីពី បញ្ជីឈ្មោះមេឃុំ ចៅសង្កាត់ស្ត្រី អាណត្តិទី៥*)

គួរកត់សម្គាល់ថា រាជធានី ខេត្តដែលមានមេឃុំ ចៅសង្កាត់ស្ត្រីច្រើនជាងគេ ដូចជា **ខេត្តកណ្ដាល**ចំនួន**១៨នាក់ ខេត្តសៀមរាប**ចំនួន**១៨នាក់ រាជធានីភ្នំពេញ**មានចំនួន**១៥នាក់ ខេត្តកំពង់ឆ្នាំង**ចំនួន**១៥នាក់ ខេត្តស្វាយរៀង**ចំនួន**១៥នាក់** និង**ខេត្តបាត់ដំបង**ចំនួន**១២នាក់** ។ ទោះបីចំនួនមេឃុំ ចៅសង្កាត់ស្ត្រីមានការកើនឡើងក្នុងអាណត្តិទី៥នេះក៏ដោយ ប៉ុន្តែជាចំនួន**តិចតួចបំផុត** ខណៈដែលមេឃុំ ចៅសង្កាត់បុរសមានចំនួនដ៏ច្រើនលើសលុប ១ ៤៧៩នាក់ ស្មើនឹង ៨៩,៥% នៃ១៦៥២ឃុំ សង្កាត់ ។ យោងតាមការសិក្សាស្រាវជ្រាវរបស់អង្គការសង្គមស៊ីវិលរកឃើញថាតួនាទីស្ត្រីជាមេឃុំ/ចៅសង្កាត់ធ្វើការមានសិទ្ធិអំណាចពេញលេញនិងធ្វើការមានប្រសិទ្ធភាពជាងស្ត្រីដែលមានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

## ករណីសិក្សា ៖ ភាពលេចធ្លោរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

### *ករណីសិក្សាទី១*



«មូលហេតុដែលខ្ញុំបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ ជាមេឃុំ និងបានជាប់ឆ្នោតជាច្រើនអាណត្តិគឺដោយសារតែគណបក្សរបស់ខ្ញុំមើលឃើញពីសមត្ថភាព ប្រជាប្រិយភាព និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាក្នុងឃុំ និងវិធីសាស្ត្រក្នុងការប្រាស្រ័យទាក់ទងរបស់ខ្ញុំជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ ជាងនេះទៅទៀតខ្ញុំមានការគាំទ្រពីគ្រួសារ និងអ្នកជិតខាង ដោយមើលឃើញពីភាពរួសរាយ និងការយកចិត្តទុកដាក់ក្នុងការស្វះស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋ ចុះពិនិត្យមើលផ្ទាល់ដល់មូលដ្ឋាន មិនគិតថាយប់អាធ្រាត ឬការងាររវល់យ៉ាងណានោះទេ ឱ្យតែប្រជាពលរដ្ឋមករកខ្ញុំតែងតែដោះស្រាយជូនភ្លាម *» ។*

លោកស្រី **ហៀង សុផល** ជាបេក្ខជនលេខរៀងទី១មកពីគណបក្សប្រជាជនកម្ពុជា និងបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ ជាមេឃុំ មេព្រីង ស្រុកបាជាយ ខេត្តកំពង់ចាម ក្នុងអាណតិទី៥នេះ

(ឆ្នាំ២០២២ ដល់ ឆ្នាំ២០២៧) ដែលមាន សមាជិកក្រុមប្រឹក្សាឃុំសរុប ៥នាក់ ក្នុងនោះស្ត្រី២នាក់ ស្មើនឹង ៤០% ដែលមានបីគណបក្សនយោបាយ ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) | គណបក្សប្រជាជនកម្ពុជា | (ស្រី) |
| ២. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១) | គណបក្សខ្មែរស្រឡាញ់ជាតិ | (ប្រុស) |
| ៣. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២) | គណបក្សភ្លើងទៀន | (ប្រុស) |
| ៤. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៥. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ស្រី) |

នៅក្នុងឃុំមេព្រីងនេះ មាន ៥ភូមិ និងប្រជាជនសរុប ១ ៧០០គ្រួសារ ស្មើនឹង ៦ ៧៥២នាក់ ។ បច្ចុប្បន្ន លោកស្រី **ហៀង សុផល** មានអាយុ៦០ឆ្នាំ ជាស្ត្រីមេម៉ាយ មានកូនបីនាក់ ស្រី១នាក់ ប្រុស២នាក់ រស់នៅឃុំមេព្រីង ស្រុកបាធាយ ខេត្តកំពង់ចាម។

លោកស្រីមានប្រវត្តិ បទពិសោធការងារ និងកំរិតវប្បធម៌ដូចតទៅ ៖

- បញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៩
- ឆ្នាំ១៩៩៣ ជាប់ជាអ្នកអភិវឌ្ឍឃុំ
- ឆ្នាំ១៩៩៧ ជាប្រធានសមាគមនារី
- ឆ្នាំ១៩៩៩ ជាអ្នកស្ម័គ្រចិត្តភូមិ (អង្គការយ៉ាចារ)
- ឆ្នាំ២០០២ ជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ បានរយៈពេល២ឆ្នាំឡើងជាមេឃុំ ដោយសារមេឃុំចាស់មានបញ្ហាសុខភាព និងជាប់ជាមេឃុំរហូតដល់បច្ចុប្បន្ន ។

លោកស្រី **ហៀង សុផល** បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំមេព្រីង ចំនួន៥អាណត្តិ (ពីអាណត្តិទី១ ដល់អាណត្តិទី៥) ។ អាណត្តិទី១ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និងនៅពាក់កណ្ដាលអាណត្តិទី១ ដល់អាណត្តិទី៥ ជាប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំស្ត្រី ។

«មូលហេតុដែលលោកស្រី **ហៀង សុផល** ចូលប្រឡូកក្នុងវិស័យនយោបាយ ដោយសារតែលោកស្រីចង់ចូលរួមជួយសង្គមដោយផ្ទាល់ និងការពារផលប្រយោជន៍ស្ត្រី ព្រមទាំងដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃក្នុងគ្រួសារផង ជាពិសេសដោយមានការជំរុញលើកទឹកចិត្តពីគ្រួសារ និងមិត្តិភក្តិជិតខាង » ។ លោកស្រីបានបញ្ជាក់ថា « *ដំបូងឡើយ ខ្ញុំមិនចាប់អារម្មណ៍លើការងារនេះទេ តែដោយមានការជំរុញពីមិត្តភក្តិ អ្នកជិតខាងខ្ញុំក៏សាកល្បង ។ បន្ទាប់ពីទទួលបានការគាំទ្រពីប្រជាពលរដ្ឋក្នុងភូមិ ខ្ញុំក៏ចាប់ផ្ដើមពេញចិត្តនឹងការងារក្នុងឃុំ ដោយបានជួយដល់ជនងាយរងគ្រោះ ដូចជា ស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា ជាដើម។* »។

លោកស្រី **ហៀង សុផល** បានប្រាប់ឱ្យដឹងទៀតថា « *មូលហេតុដែលខ្ញុំបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាឃុំ ជាមេឃុំ និងបានជាប់ឆ្នោតជាច្រើនអាណត្តិ គឺដោយសារតែគណបក្សរបស់ខ្ញុំមើលឃើញពីសមត្ថភាព ប្រជាប្រិយភាព និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាក្នុងឃុំ និងវិធីសាស្ត្រក្នុងការប្រាស្រ័យទាក់ទងរបស់ខ្ញុំជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន* » ។ បន្ថែមលើនេះទៀត លោកស្រីមានការគាំទ្រពីគ្រួសារនិង

អ្នកជិតខាងដោយពួកគេមើលឃើញពីសមត្ថភាព ភាពរួសរាយ និងការយកចិត្តទុកដាក់ក្នុងការស្វះស្វែងរកដំណោះស្រាយជូនប្រជាពលរដ្ឋ ចុះពិនិត្យមើលផ្ទាល់ដល់មូលដ្ឋាន មិនគិតថាយប់អាធ្រាត ឬ ការងាររវល់យ៉ាងណានោះទេ ឱ្យតែប្រជាពលរដ្ឋមករកលោកស្រី គឺលោកស្រីដោះស្រាយជូនភ្លាមៗ ។ ចំណែកឯបុរសនៅក្នុងឃុំក៏មានការលើកទឹកចិត្ត និងកោតសរសើរពីភាពក្លាហានរបស់លោកស្រីក្នុងការដឹកនាំភូមិ ឃុំប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

វិធីសាស្ត្រដែលលោកស្រីប្រើប្រាស់ ដើម្បីទាក់ទាញការគាំទ្រពីម្ចាស់ឆ្នោតក្នុងឃុំទាំងពេលដឹកនាំឃុំនិងទាំងពេលឃោសនាបោះឆ្នោត គឺ លោកស្រីចុះទៅដោះស្រាយជូនប្រជាពលរដ្ឋដល់កន្លែង និងដោះស្រាយជូនប្រជាពលរដ្ឋភ្លាមៗ ទាំងបញ្ហា អំពើហិង្សា ក្មេងទំនើង និងការផ្តល់សេវាកម្មផ្សេងៗជូនប្រជាពលរដ្ឋ ។

ក្នុងជីវិតនយោបាយរបស់លោកស្រី **ហៀង សុផល** ពុំឃើញមានការប្រឈម ឬក៏ឧបសគ្គរាំងណាមួយដល់ដំណើរការឈោងចាប់យកតំណែងជាស្ត្រីដឹកនាំនៅឃុំ សង្កាត់ឡើយ ។ លោកស្រីពិតជាអ្នកនយោបាយមូលដ្ឋានដែលពោរពេញដោយសក្តានុពល មានភាពរឹងមាំ មានសំណាងបានទទួលការគាំទ្រពេញលេញពីគណបក្សរបស់ខ្លួន និងមានឱកាសយ៉ាងទូលំទូលាយក្នុងជីវិតនយោបាយរបស់លោកស្រី ។

សម្រាប់អាណត្តិទី៥នៃក្រុមប្រឹក្សាឃុំ សង្កាត់នេះ លោកស្រីបានប្តេជាចិត្តថា « *លោកស្រីនឹងបន្តសកម្មភាពដែលបានផ្តល់សេវាល្អៗកន្លងមកជូនប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំ និងខិតខំបន្ថែមទៀតធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋរស់នៅដោយសុខុដុមរមនា និងមានការអភិវឌ្ឍភូមិ ឃុំមេព្រីង* »។

ដើម្បីបង្កើនចំនួនបេក្ខជនស្ត្រីឈរឈ្មោះសម្រាប់ការបោះឆ្នោតអាណត្តិក្រោយ លោកស្រីបានលើក ទឹកចិត្តស្ត្រីក្នុងឃុំថា « ស្ត្រីត្រូវមានភាពក្លាហានក្នុងការប្រឡូកក្នុងវិស័យនយោបាយ កុំខ្លាច ឬគិតថាខ្លួនធ្វើមិនបានពីព្រោះពេលចូលរួមក្នុងកិច្ចការនយោបាយនឹងបានរៀនសូត្រជាបន្តបន្ទាប់។ ជាពិសេសមាន ក្រុមកិច្ចការនារី ក្រុមកិច្ចការយេនឌ័រជួយជ្រោមជ្រែងបន្ថែមទៀត ជួយពន្យល់ឱ្យស្ត្រីបានយល់ដឹង និងអភិវឌ្ឍន៍ សមត្ថភាពរបស់ខ្លួន » ។

លោកស្រី **ហៀង សុផល** បានសំណូមពរថា ៖ សូមឱ្យស្ត្រីមានភាពក្លាហានឡើងក្នុងការចូលរួម និងសូមឱ្យមានការយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពខ្លួនឯង ដើម្បីបង្ហាញពីសក្តានុពលរបស់ស្ត្រីក្នុងការចូលរួមអភិវឌ្ឍន៍សង្គម ។ ទន្ទឹមនឹងនេះ សូមគណបក្សនយោបាយបន្តផ្តល់ឱកាស និងគាំទ្រស្ត្រីដើម្បីឱ្យស្ត្រីបានប្រើប្រាស់សក្តានុពលរបស់ខ្លួនក្នុងការចូលរួមដឹកនាំនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។

មូលហេតុចម្បងដែលជម្រុញឱ្យនាងខ្ញុំចូលប្រឡូកការងារក្នុងវិស័យនយោបាយ គឺចង់ជួយសង្គមដោយផ្ទាល់ ជួយលើកកំពស់ស្ត្រី លើក កំពស់កុមារ រួមទាំងជួយកុមារកំព្រា និងស្ត្រី មេម៉ាយ ។ មានការគាំទ្រពីសំណាក់គ្រួសារ ដោយពួកគាត់បានផ្តល់នូវការលើកទឹកចិត្ត និងជួយជម្រុញបន្ថែម ជាពិសេសមានការចាត់ចែងសព្វបែបយ៉ាងពីស្វាមីចំពោះនាងខ្ញុំ ។



លោកស្រី **ថោង សារ៉ុម** ជាបេក្ខជនឈរឈ្មោះលេខរៀងទី១ មកពីគណបក្សភ្លើងទៀននិងបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ និងជាជំទប់ទី២ឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ ក្នុងអាណត្តិទី៥នេះ (ឆ្នាំ២០២២ ដល់ ឆ្នាំ២០២៧) ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សរុប ៧នាក់ ក្នុងនោះស្ត្រី **៣នាក់ (៤៣%)** មានពីរគណបក្សនយោបាយ ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ២. សមាជិកក្រុមប្រឹក្សាឃុំ និងជាជំទប់ទី១ | គណបក្សប្រជាជនកម្ពុជា | (ស្រី) |
| ៣. សមាជិកក្រុមប្រឹក្សាឃុំ និងជាជំទប់ទី២ | គណបក្សភ្លើងទៀន | (ស្រី) |
| ៤. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ស្រី) |
| ៥. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៦. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |
| ៧. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ប្រុស) |

បច្ចុប្បន្ន លោកស្រី **ថោង សារ៉ុម** មានអាយុ ៥១ឆ្នាំ មានស្វាមីឈ្មោះ **គិន ភុយ** និងមានកូនស្រីចំនួន ៣នាក់ រស់នៅភូមិស្អាង ឃុំស្អាង ស្រុកជ័យសែន ខេត្តព្រះវិហារ ហើយលោកស្រីបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៤ ។

លោកស្រី **ថោង សារ៉ុម** គឺជាបេក្ខជនស្ត្រីដែលបានជាប់ឆ្នោតជាលើកដំបូង(ជាប់ឆ្នោតថ្មី) ជាសមាជិកក្រុមប្រឹក្សា និងជាជំទប់ទី២នៃឃុំស្អាង ក្នុងអាណត្តិទី៥នេះ ដោយទទួលបន្ទុកការងារជាអ្នកផ្តល់ព័ត៌មាន និងជួយណែនាំជូនប្រជាពលរដ្ឋពេលដែលមកធ្វើឯកសារផ្សេងៗ និងជាអ្នកចាំទទួលឯកសារ ។

*« មូលហេតុចម្បងដែលជម្រុញឱ្យនាងខ្ញុំចូលប្រឡូកការងារក្នុងវិស័យនយោបាយ គឺនាងខ្ញុំចង់ជួយសង្គមដោយផ្ទាល់ ជួយលើកកំពស់ស្ត្រី លើកកំពស់កុមារ រួមទាំងជួយកុមារកំព្រានិងស្ត្រីមេម៉ាយ ។ បន្ថែមលើ*

*នេះទៀត ដោយសារនាងខ្ញុំទទួលបានការគាំទ្រ ជម្រុញលើកទឹកចិត្តយ៉ាងពេញទំហឹងពីក្រុមគ្រួសារ ជាពិសេសមានការគាំទ្រ និងចាត់ចែងសព្វបែបយ៉ាងពីស្វាមីក្នុងការឈរឈ្មោះ និងការធ្វើសកម្មភាពនយោបាយ»* លោកស្រីបានបញ្ជាក់យ៉ាងច្បាស់ ។

« ការណ៍ដែលលោកស្រីបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំស្អាង អាណត្តិទី៥នេះ គឺដោយសារតែលោកស្រីជាស្ត្រីដែលមានភាពរួសរាយរាក់ទាក់ ហើយលោកស្រីបានចូលរួមសកម្មភាពនៅក្នុងភូមិ ឃុំរបស់ខ្លួនដែលជាកត្តាមួយធ្វើឱ្យប្រជាពលរដ្ឋមានការពេញចិត្ត ស្រលាញ់ និងគាំទ្រ ហើយជឿជាក់លើលោកស្រីក្នុងការបម្រើជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ។ កត្តាមួយទៀត ដោយសារតែមើលឃើញថាលោកស្រីជាមនុស្សតស៊ូ និងមានភាពក្លាហាន »។

វិធីសាស្ត្រដែលនាងខ្ញុំបានប្រើប្រាស់ ដើម្បីទាក់ទាញការគាំទ្រពីសំណាក់ប្រជាពលរដ្ឋ ម្ចាស់ឆ្នោតក្នុងឃុំពេលឃោសនាបោះឆ្នោតមានដូចជា ៖

- ធ្វើការស្ទង់មតិប្រជាពលរដ្ឋ ដោយត្រូវរិះរកមធ្យោបាយយ៉ាងណាដើម្បីធ្វើឱ្យពួកគាត់ចូលចិត្តនិងពេញចិត្ត ។
- និយាយនូវពាក្យសំដីផ្អែមល្ហែមឱ្យប្រជាពលរដ្ឋជឿទុកចិត្តមកលើរូបនាងខ្ញុំ
- ចូលរួមជួយប្រជាពលរដ្ឋដោយផ្ទាល់ រួមទាំងបានចូលរួមជួយរាល់សកម្មភាពដែលមាននៅក្នុងភូមិឃុំ
- ដើរចែកសន្លឹកខិតប័ណ្ណរបស់គណបក្សភ្លើងទៀនជូនប្រជាពលរដ្ឋ
- និយាយផ្សព្វផ្សាយ បើប្រជាពលរដ្ឋពេញចិត្តគណបក្សភ្លើងទៀនរបស់នាងខ្ញុំ សូមជួយបោះឆ្នោតជូននាងខ្ញុំផង ។

ក្នុងជីវិតនយោបាយរបស់លោកស្រី **ថោង សារ៉ុម** ពុំឃើញមានការប្រឈម ឬក៏ឧបសគ្គរាំងណាមួយដល់ដំណើរការឈោងចាប់យកតំណែងជាស្ត្រីដឹកនាំនៅឃុំ សង្កាត់ឡើយ ។ លោកស្រីពិតជាអ្នកនយោបាយមូលដ្ឋានម្នាក់មានភាពក្លាហាន មានសំណាងបានទទួលការគាំទ្រពេញលេញពីគណបក្សរបស់ខ្លួន មានការចាត់ចែងយ៉ាងពេញទំហឹងពីស្វាមី និងទទួលបានឱកាសយ៉ាងទូលំទូលាយក្នុងជីវិតនយោបាយរបស់លោកស្រីបើទោះបីលោកស្រីទើបតែចូលប្រឡូកក្នុងកិច្ចការនយោបាយ និងបានឈរឈ្មោះជាបេក្ខជនជាលើកដំបូងក៏ដោយ ។

សម្រាប់អាណត្តិទី៥នៃក្រុមប្រឹក្សាឃុំ សង្កាត់នេះ លោកស្រីបានសន្យា និងប្តេជ្ញាចិត្តថា *« នាងខ្ញុំសន្យាដឹកនាំឃុំស្អាងឱ្យកាន់តែមានការរីកចម្រើន និងមានសន្តិសុខ សណ្តាប់ធ្នាប់ល្អ »*។

លោកស្រី **ថោង សារ៉ុម** បានសំណូមពរដូចតទៅ ៖

- សូមឱ្យមានបេក្ខជនស្ត្រីឈរឈ្មោះជាក្រុមប្រឹក្សាឃុំ សង្កាត់ កាន់តែច្រើនសម្រាប់អាណត្តិក្រោយៗទៀត
- សូមស្ត្រីទាំងឡាយកុំមានការអៀនខ្មាស់ ហើយកុំគិតថាខ្លួនមិនអាចធ្វើបាន
- ស្ត្រីត្រូវមានភាពជឿជាក់លើសក្តានុពលរបស់ខ្លួន សមត្ថភាពខ្លួនឯង ថាអាចធ្វើបាន

ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មាន**រយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២២** គណបក្សនយោបាយទាំង១៧ បានធ្វើសកម្មភាពឃោសនាដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវកម្មវិធីនយោបាយរបស់ខ្លួនក្នុងការដឹកនាំ និងអភិវឌ្ឍ ឃុំ សង្កាត់ ក្នុងនោះក៏បានបង្ហាញនូវកម្មវិធីនយោបាយទាក់ទងនឹងការដោះស្រាយបញ្ហាស្ត្រី និងកុមារ ក្នុងអាណត្តិទី៥នេះផងដែរ។

កម្មវិធីនយោបាយ និងការសន្យាសំខាន់របស់គណបក្សនយោបាយខាងក្រោមនេះ បានដកស្រង់ចេញពីឯកសារនៅក្នុងគេហទំព័ររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងបានដកស្រង់ចេញពីរបាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែលស្តីពី «ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២» ព្រមទាំងបានដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន**៥ខេត្ត** គឺ **ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ** ។

គណបក្សនយោបាយប្រមាណ៣០%ក្នុងចំណោមគណបក្សនយោបាយ១៧ បានគិតគូរក្នុងការដោះស្រាយបញ្ហាស្ត្រី និងកុមារ ៖

### តារាងទី១៦ ៖ កម្មវិធីនយោបាយថ្នាក់ជាតិរបស់គណបក្សដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ

| ល.រ | កម្មវិធីនយោបាយរបស់គណបក្ស | ឈ្មោះគណបក្សនយោបាយ |
|---|---|---|
| ១ | ទប់ស្កាត់ការជួញដូរគ្រឿងញៀន ល្បែងស៊ីសង ចោរកម្ម និងការជួញដូរផ្លូវភេទទៅលើស្ត្រី | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន<br>• ហ្វ៊ុនស៊ិនប៉ិច<br>• ខ្មែររួបរួមជាតិ |
| ២ | • លុបបំបាត់ការជួញដូរស្ត្រី និងកុមារ<br>• លុបបំបាត់គ្រឿងញៀនដែលជះឥទ្ធិពលដ៏ធំមកលើកូនខ្មែរគ្រប់រូប | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន<br>• ខ្មែររួបរួមជាតិ |
| ៣ | អប់រំជាសាធារណៈ អំពី ការរំលោភផ្លូវភេទ និងការជួញដូរស្ត្រី និងកុមារ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |

| | | |
|---|---|---|
| ៤ | បង្កើតមូលនិធិជូនដល់ជនដែលងាយរងគ្រោះ ដូចជា ចាស់ជរា ស្ត្រីមានផ្ទៃពោះ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន<br>• ហ្វ៊ុនស៊ីនប៉ិច |
| ៥ | រៀបចំឱ្យមានសហគមន៍ជួយគ្នាទៅវិញទៅមកនៅតាមមូលដ្ឋាន ជាពិសេសជួយគាំពារដល់ចាស់ជរា ជនក្រីក្រ ជនគ្មានទីពឹង កុមារកំព្រា និងជនពិការ ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ៦ | ខិតខំស្វែងរកការងារជូនរាស្ត្រ ជាពិសេសស្ត្រីនៅក្នុងមូលដ្ឋាន | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ៧ | បង្កលក្ខណៈងាយស្រួលក្នុងការសិក្សា និងកីឡាជូនយុវជន យុវនារីក្នុងមូលដ្ឋាន ដើម្បីកាយសម្បទារឹងមាំ និងប្រាជ្ញាភ្លឺថ្លា ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ៨ | ជំរុញគ្រូពេទ្យឱ្យយកចិត្តទុកដាក់ពិនិត្យ និងព្យាបាលជំងឺជូនប្រជារាស្ត្រនៅមណ្ឌលសុខភាព ពិសេសចាស់ជរា មាតា ទារក និងទទួលសង្គ្រោះបន្ទាន់ដោយគ្មានការរើសអើងព្រមទាំងរៀបចំឱ្យមានរថយន្តឬមធ្យោបាយសមស្របអាចដឹកជញ្ជូនអ្នកជំងឺសង្គ្រោះបន្ទាន់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ជាពិសេសមិនឱ្យអ្នកជំងឺស្លាប់ដោយខ្វះប្រាក់សម្រាប់ព្យាបាលឡើយ ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ៩ | លើកស្ទួយការអភិវឌ្ឍន៍ស្ត្រី និងកុមារឱ្យបានរីកចំរើនគ្រប់វិស័យ នូវតំរូវការនៃប្រជាពលរដ្ឋចង់បាន ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន<br>• ហ្វ៊ុនស៊ីនប៉ិច |
| ១០ | អភិវឌ្ឍន៍ឃុំ សង្កាត់ឱ្យរីកចំរើនប្រកបដោយចីរភាពលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំ សុខាភិបាល និងយេនឌ័រ ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ១១ | បណ្តុះបណ្តាលចំណេះដឹង និងចំណេះធ្វើដល់កុមារ យុវជន យុវតីដោយផ្តល់នូវអាហាររូបករណ៍ ទំនាក់ទំនងអង្គការក្រៅប្រទេសដើម្បីជួយដល់កុមារ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន<br>• ហ្វ៊ុនស៊ីនប៉ិច |
| ១២ | ជួយលើកតម្កើងស្ត្រីឱ្យមានគំនិតច្នៃប្រឌិតតាមតំបន់នីមួយៗ ដោយតម្បាញតាមផ្ទះ ផ្តល់ជំនួយសម្រាប់កុមារ ជនពិការ ក្មេងកំព្រា។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ១៣ | • លើកស្ទួយសិទ្ធិកុមារ កុមារកំព្រា កុមារពិការ កុមារមក | • ប្រជាជនកម្ពុជា |

| | | |
|---|---|---|
| | ពីគ្រួសារក្រីក្រ ។<br>• បង្កើនការអប់រំ ការស្តារនីតិសម្បទានិងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមាររងគ្រោះ ។ | • ភ្លើងទៀន |
| ១៤ | លើកតម្កើងការគោរពសិទ្ធិសេរីភាពប្រជារាស្ត្រ និងសមភាពយេនឌ័រដែលជាគោលការណ៍គ្រឹះនៃលទ្ធិប្រជាធិបតេយ្យ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន<br>• ខ្មែរស្រឡាញ់ជាតិ |
| ១៥ | បង្កើតគោលនយោបាយសមភាពយេនឌ័រ ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការផ្តល់អំណាចដល់ស្ត្រីក្នុងការធ្វើសេចក្រីសម្រេចចិត្ត ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ១៦ | ជានាប្រសិទ្ធភាព និងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិស្ត្រី សិទ្ធកុមារ និងសិទ្ធិជនជាតិដើមភាគតិច ហើយជម្រុញឱ្យមានការចូលរួមពីស្ត្រីនៅគ្រប់វិស័យ ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ១៧ | រៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលស្ត្រីដើម្បីបង្កើនសមត្ថភាពយល់ដឹង និងការចូលរួមក្នុងកិច្ចការសេដ្ឋកិច្ច សង្គម និងនយោបាយ ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ១៨ | គាំទ្រដល់យុវជន និងយុវនារីដែលមិនមានលទ្ធភាពបន្តការសិក្សាដល់ថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យឱ្យទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងទុនសម្រាប់បង្កើតមុខរបរដោយខ្លួនឯង ។ យើងនឹងជ្រើសរើសមន្ត្រីជំនាញយ៉ាងតិច១រូបក្នុង១ឃុំឱ្យជួយតម្រង់ទិស និងគាំទ្រដល់យុវជនដើម្បីទទួលបានការងារល្អ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |
| ១៩ | ជានាផ្តល់នូវសេវាសាធារណៈជូនមន្ត្រីរាជការ កម្មករ-កម្មការិនីរោងចក្រ និងស្ត្រី-បុរសកម្មករសំណង់ ស្ត្រី-បុរសអាជីវករ ព្រមទាំងសិស្ស និស្សិត និងយុវជន-យុវនារីប្រកបដោយ គុណភាព និងប្រសិទ្ធភាព ។ | • ប្រជាជនកម្ពុជា<br>• ភ្លើងទៀន |

## តារាងទី១៧ ៖ កម្មវិធីនយោបាយរបស់គណបក្សតាមឃុំ សង្កាត់នីមួយៗ ដែលបាន សន្យាដោយបេក្ខជនស្ត្រីដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ

ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ ២០២២នេះ បេក្ខជនស្ត្រីឈរឈ្មោះបានឃោសនាតាមកម្មវិធីនយោបាយថ្នាក់ជាតិ និងបានធ្វើការសន្យាបន្ថែមទៅតាមតម្រូវការក្នុងឃុំ សង្កាត់ដោយឡែកៗពីគ្នាទាក់ទិននឹងបញ្ហាស្ត្រី និងកុមារ ។ គណបក្សខ្លះបានបង្ហាញពីសមិទ្ធិផលដែលបានកសាងទាំងអស់ក្នុងឃុំ សង្កាត់ក្នុងរយៈពេល៥ឆ្នាំកន្លងមក ។ ការសន្យាសំខាន់ៗតាមឃុំ សង្កាត់នេះបានដកស្រង់ព័ត៌មានពីបេក្ខជនស្ត្រីក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន៥ខេត្ត គឺខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តតាកែវ និងខេត្តព្រះវិហារ ។



ប្រភព ៖ Rasmei Kampuchea Daily



ប្រភព ៖ Khmer Unity

| ល.រ | កម្មវិធីនយោបាយរបស់គណបក្ស តាម ឃុំ សង្កាត់ | បេក្ខជនស្ត្រី | ឈ្មោះគណបក្សនយោបាយ |
|---|---|---|---|
| ១ | លើកកម្ពស់ការគាំពារសង្គម និង លើកកម្ពស់ ស្ថានភាពរស់នៅរបស់ស្ត្រី យុវជន កុមារ ជនមានពិការភាព ចាស់ជរា ជនជាតិភាគតិច អតីតយុទ្ធគ្រួសារក្រីក្រ និងប្រជាជនងាយ រងគ្រោះ។ | បេក្ខជនស្ត្រី ខេត្តកំពង់ឆ្នាំង | ប្រជាជនកម្ពុជា |
| ២ | លើកកម្ពស់ស្ត្រីឱ្យមានការចូលរួមយ៉ាងផុសផុល និងយកចិត្តទុកដាក់លើបញ្ហាស្ត្រីក្នុង កិច្ចការនយោបាយ។ | បេក្ខជនស្ត្រី ខេត្តកំពង់ចាម | |
| ៣ | គោរពតាមគោលការណ៍របស់បក្ស លើកកម្ពស់ស្ត្រី ជួយដល់កុមារកំព្រា ចាស់ជរា ជនទីទល់ក្រ ។ | បេក្ខជនស្ត្រី ខេត្តព្រះវិហារ | ភ្លើងទៀន |
| ៤ | លើកកម្ពស់ និងផ្តល់ឱកាសឱ្យស្ត្រីបានចូលរួម និងធ្វើការបណ្តុះបណ្តាលចំណេះដឹង ដល់ស្ត្រីបន្ថែមទៀត ។ | បេក្ខជនស្ត្រី ខេត្តកំពង់ ចាម | |

## ៤- សមាជិកស្ត្រីរបស់ គ.ជ.ប លធ.ខប គធ.ខប គឃ.សប មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងស្ត្រីក្រុមចុះឈ្មោះបោះឆ្នោត[8]

ស្ត្រីនៅតែមានចំនួនតិចតួចក្នុងតួនាទីជាអ្នកគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ខណៈដែលមានស្ត្រីស្ទើរតែ ៥០% នៅគកប និងគករ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ។

### ថ្នាក់ជាតិ

ពុំមានស្ត្រីសោះជាអ្នកដឹកនាំនៅថ្នាក់ជាតិជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ក្នុងចំណោមសមាសភាពទាំង៩រូប និងជាអគ្គលេខាធិការនិងអគ្គលេខាធិការរងទាំង ៥រូប ។ មានស្ត្រីចំនួន ១៣០នាក់ (២០,៣%) នៃចំនួនសរុប ៦៣៩នាក់ ជាបុគ្គលិកបម្រើការនៅក្នុងអគ្គលេខាធិការដ្ឋាននៃគ.ជ.ប ចំនួននេះបាន**កើនឡើង** **<u>៧,៣%</u>** បើធៀបនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ មានស្ត្រីតែ **៤២នាក់ (១៣%)** នៃចំនួនសរុប ៣២៤នាក់ ។ ស្ត្រីជាមន្ត្រីជាប់កិច្ចសន្យារយៈពេលវែង មានចំនួន **១៤២នាក់ (៣៥,៣%)** នៃចំនួនសរុប ៤០២នាក់ ។ ជាមួយគ្នានេះ ស្ត្រីជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីមានចំនួន **១០៦នាក់ (៣២%)** នៃចំនួនសរុប ៣៣១នាក់ ចំនួននេះមាន**ភាគរយប្រហាក់ប្រហែល**នឹង អាណត្តិទី៤ ឆ្នាំ២០១៧ មានភាគរយ ៣១,៦% ។

### ថ្នាក់ក្រោមជាតិ

ស្ត្រីនៅតែមានចំនួនតិចតួចនៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមៗ ដូចជា លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត(លធ.ខប)មានស្ត្រីចំនួន ៣៨នាក់ (១៣,៥%)នៃចំនួនសរុប២៨១នាក់។ មន្ត្រីជាប់កិច្ចសន្យារយៈពេលវែងនៅលធ.ខប និងថ្នាក់ រាជធានី ខេត្ត ចំនួន ១១១នាក់ ក្នុងនោះស្ត្រីមាន ចំនួន ៣២នាក់ ស្មើនឹង ២៨,៨% ។ ចំណែកឯមន្ត្រីជាប់កិច្ច សន្យារយៈពេលខ្លីនៅលធ.ខប ចំនួន៥១៦នាក់ ក្នុងនោះ ស្ត្រីមានចំនួន៤៧នាក់ (៩,១%) ។




[8] របាយការណ៍បូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ថ្លែងដោយឯកឧត្តម សោម សូរីដា ទីប្រឹក្សាគ.ជ.ប និងជាអគ្គលេខាធិការរង គ.ជ.ប

មន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីជាគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គធ.ខប) និងមន្ត្រី គធ.ខប ចំនួន ១ ០២៣នាក់ ក្នុងនោះស្ត្រី មានចំនួន ១៤១នាក់ ស្មើនឹង ១៣,៨% គឺមានការកើនឡើងបន្តិច **១,២%** បើធៀបនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ដែលស្ត្រីមានចំនួន ១១៤នាក់ ស្មើនឹង ១២,៦% ។ រីឯ មន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីជាគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ចំនួន ៨ ៣០២នាក់ ក្នុងនោះស្ត្រីមានចំនួន១ ២៤៨នាក់ (១៥%) ចំនួននេះមាន **ភាគរយប្រហាក់ប្រហែល**នឹងអាណត្តិទី៤ ឆ្នាំ២០១៧ មាន១៤,៩% ។ ចំណែកឯ សមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) មានចំនួនសរុប ៤ ៩៥០នាក់ ក្នុងនោះស្ត្រីជាមន្ត្រីក.ច.បចំនួន **៨២៣នាក់ (១៦,៦%)** ប្រចាំឆ្នាំ២០២១ ចំនួននេះមានការ**ថយចុះ** **៣,៥%** បើធៀបនឹងឆ្នាំ២០១៦ មាន **២០,១%** ។

## ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត





**ប្រភព ៖ VOD Khmer**

**ចំនួនស្ត្រីកាន់តែច្រើន**នៅថ្នាក់ទាប ដូចជា មន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីជា គណៈកម្មការការិយាល័យបោះឆ្នោត (គកប) និងគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត(គករ) មានស្ត្រីចំនួន**៧០ ៤៥១នាក់** ស្មើនឹង **៤៩,៧%** នៃចំនួនសរុប ១៤១ ៦១២នាក់ ។ ចំនួននេះបាន**កើនឡើង ៥,៩%** បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ ស្ត្រី មានចំនួន ៥៨ ១៧៦នាក់ ស្មើនឹង ៤៣,៨% ។

## ក្រាហ្វិកទី១៨




ប្រភព ៖ គ.ជ.ប

**ក្រាហ្វិកទី១៩ ៖ តួនាទីរបស់ស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត**




ប្រភព ៖ គ.ជ.ប

របាយការណ៍សង្កេតការណ៍របស់ខុមហ្វ្រែល GADC និង BCV ស្តីពី« *ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២*» បានរកឃើញថា នៅថ្ងៃបោះឆ្នោត ភាគរយសរុបនៃមន្ត្រីការិយាល័យបោះឆ្នោតជាស្ត្រី និងបុរស ស្ទើរតែមានសមភាពរវាងភេទ គឺ ស្ត្រី ចំនួន **២៨៤នាក់ ស្មើនឹង ៤៩% និងបុរសចំនួន ២៩៨នាក់ ស្មើនឹង ៥១,២%** នៃចំនួនសរុប**៥៨២** ក្នុងចំណោម **៩៧**ការិយាល័យបោះឆ្នោត ។ ទោះបីយ៉ាងណា ស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោត**ភាគច្រើន**មានតួនាទីជា**សមាជិក**ចំនួន**៥៦%** ខណៈដែលតួនាទីជា**ប្រធាន**មាន**តិចតួច ៦% ប៉ុណ្ណោះ ។ ចំណែកឯ** តួនាទីជា**លេខាធិការ**មានចំនួន **២២%** និងជា**អនុប្រធាន**មានចំនួនតែ**១៦%** ។ ជាមួយគ្នានេះដែរ យើងឃើញមានការិយាល័យបោះឆ្នោតលេខ ០២៣៦ នៅភូមិត្រពាំងទន្ទឹម ឃុំរមទម ស្រុករវៀង ខេត្តព្រះវិហារ មានសុទ្ធតែស្ត្រីទាំងអស់ ជាមន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

## ៥- អ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយជាស្ត្រី

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ បណ្តាស្ថានទូតនានាប្រចាំនៅកម្ពុជា និងគណបក្សនយោបាយ បានដាក់ពង្រាយអ្នកសង្កេតការណ៍ និងតំណាងរបស់ខ្លួនតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នៃរាជធានី ខេត្តនីមួយៗដើម្បីចូលរួមសង្កេត ឃ្លាំមើលដំណើរការរៀបចំការបោះឆ្នោត ។ តាមតួលេខផ្លូវការរបស់ គ.ជ.ប

បានបង្ហាញនូវចំនួនអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ ភ្ញៀវពិសេស និងភ្នាក់ងារគណបក្សនយោបាយដូចខាងក្រោម[9] ៖



ប្រភព ៖ ខុមហ្វ្រែល

## អ្នកសង្កេតការណ៍ជាតិជាស្ត្រី

**អ្នកសង្កេតការណ៍ជាតិជាស្ត្រី**ដែលគ.ជ.បបានអនុញ្ញាតិឱ្យចូលរួមសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មានចំនួន **៤៥ ៤៧១នាក់** ស្មើនឹង**៦០,៧%** ក្នុងនោះ**ស្ត្រីពិការ** ចំនួន **៤នាក់** នៃចំនួនសរុប **៧៤ ៨៨៥នាក់** មកពីសមាគម-អង្គការមិនមែនរដ្ឋាភិបាលចំនួន៧២ ។ ចំនួននេះ បានកើនឡើង **៧,៧%** បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មានស្ត្រីជាអ្នកសង្កេតការណ៍ចំនួន**៥៣%** ។

គួរកត់សម្គាល់ថា ការបោះឆ្នោតលើកនេះ **អ្នកសង្កេតការណ៍ជាស្ត្រីមានចំនួនច្រើនលើសលុប** ដាក់ស្តែងសមាគមនារីកម្ពុជាដើម្បី សន្តិភាព និងអភិវឌ្ឍន៍ (CWPD)បានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីរបស់ខ្លួនស្មើរតែ១០០% ទូទាំងប្រទេស និងច្រើនជាងមុន មានចំនួន **២៦ ០៩៩នាក់** ស្មើនឹង **៩៩,៩%** នៃចំនួនសរុប ២៦ ១០២នាក់ ។ ចំណែកឯ អង្គការខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួន សរុបទាំងអស់ចំនួន **១ ៩៤៩នាក់** ក្នុងនោះ ស្ត្រីចំនួន **៨៤៥នាក់** ស្មើនឹង **៤៣,៣%** ។ ចំនួននេះ គឺ បាន**ថយចុះ**ប្រមាណ **១២ ៦៣១នាក់ (៨៦,៦%)** បើធៀបនឹងការបោះឆ្នោត អាណត្តិទី៤ ឆ្នាំ២០១៧ មានចំនួនអ្នកសង្កេតការណ៍សរុបដល់ទៅ ១៤ ៥៨០នាក់ ខណៈដែលចំនួនស្ត្រីក៏មានការ **ថយចុះ**ប្រមាណ **៥ ៣០៨នាក់** ។ ដោយឡែកសហភាពសហព័ន្ធយុវជនកម្ពុជា បានដាក់ពង្រាយអ្នកសង្កេតការណ៍របស់ខ្លួនទូទាំងប្រទេស**ច្រើនជាងគេ**ចំនួន **៣៩ ៨១៥នាក់** ក្នុងនោះស្ត្រី ចំនួន **១៦ ៤២១នាក់** ស្មើនឹង **៤១,២%** សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ ។ ( *ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ ៥)*

មិនមានការប្រឈមគួរឱ្យកត់សម្គាល់មកលើអ្នកសង្កេតការណ៍ស្ត្រី របស់ខុមហ្វ្រែលនិងអង្គការបីស៊ីវី អ្នកសង្កេតការណ៍ស្ត្រី-បុរសរបស់ អង្គការហ្វេតស៊ី នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។ មន្ត្រីការិយាល័យបោះឆ្នោតបានផ្តល់អាទិភាពឱ្យអ្នកសង្កេតការណ៍ស្ត្រី-បុរសទាំងនោះបានបោះឆ្នោតមុន និងបានអនុញ្ញាតឱ្យចូលសង្កេតការណ៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតស្របតាមបទបញ្ញា និងនីតិវិធីបោះឆ្នោត ។ ទោះបីយ៉ាងណា ការិយាល័យបោះឆ្នោតចំនួន១ ក្នុងចំណោម**៩៧ ការិយាល័យបោះឆ្នោត**



ប្រភព ៖ ខុមហ្វ្រែល

[9] សេចក្តីប្រកាសព័ត៌មាន អំពីលទ្ធផលបណ្តោះអាសន្ននៃការផ្តល់ប័ណ្ណជូនអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិ និងភ្ញៀវពិសេសដែលត្រូវសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដោយគ.ជ.ប នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២

មានការរារាំងអ្នកសង្កេតការណ៍ជាស្ត្រី និងភ្នាក់ងារជាស្ត្រីរបស់គណបក្សនយោបាយមិនឱ្យចូលសង្កេតការណ៍ក្នុងការិយាល័យបោះឆ្នោត**លេខ០៣៧៣** នៅភូមិល្វៃ ឃុំត្រពាំង ឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

### *អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី*

**អ្នកសង្កេតការណ៍អន្តរជាតិជាស្ត្រី**ដែលគ.ជ.បបានអនុញ្ញាត មានចំនួន **៤០នាក់ ស្មើនឹង ៣៦,៤%** នៃចំនួនសរុប**១១០នាក់**ដែលមកពី សាកលវិទ្យាល័យ ក្រុមអ្នកស្រាវជ្រាវ អ្នកបកប្រែភាសា សមាគម និងអង្គការអន្តរជាតិ សរុបចំនួន១៩ ។ ចំនួនប្រុស-ស្រីនៃអ្នកសង្កេតការណ៍អន្តរជាតិនេះ មានការថយចុះ ចំនួន **២៧៤នាក់ (៧១,៣%)** ពី ៣៨៤នាក់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ មកត្រឹម១១០នាក់ក្នុងអាណត្តិទី៥ ឆ្នាំ២០២២ ខណៈដែលចំនួនស្ត្រីក៏មានការថយចុះ **៨៤នាក់** ពី ១២៤នាក់ ឆ្នាំ២០១៧ មកត្រឹម ៤០នាក់ ឆ្នាំ២០២២ ។ *(ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធ ៥)*

### *ភ្ញៀវពិសេសជាស្ត្រី*

**ភ្ញៀវពិសេសជាស្ត្រី**ដែលគ.ជ.បបានអនុញ្ញាតិដើម្បីសង្កេតលើដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ មានចំនួន **៦នាក់** ស្មើនឹង **២៦,១%** នៃចំនួនសរុបស្រី-ប្រុស ២៣នាក់ ដែលមកពី បណ្ដាស្ថានទូតមួយចំនួន និងសាកលវិទ្យាល័យបរទេសសរុបចំនួន ៥ ។

### *ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី*

**ភ្នាក់ងារគណបក្សនយោបាយជាស្ត្រី**ដែលអនុញ្ញាតិដោយ គ.ជ.ប មានចំនួន **២៦ ១៥៥នាក់ ស្មើនឹង ២៩,៧%** នៃចំនួនសរុបស្រី-ប្រុស **៨៨ ០៥០នាក់** មកពី **១៧ គណបក្សនយោបាយ** សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ។ ចំនួនសរុបនេះ បាន**ថយចុះ**: **១៧ ០២៦នាក់ (១៦,២%)** បើធៀបនឹងអាណត្តិទី៤ ឆ្នាំ២០១៧ មានចំនួន ១០៥ ០៧៦នាក់ ប៉ុន្តែចំនួនស្ត្រីមានការ**កើនឡើង** **៣ ២៣១នាក់** និងភាគរយស្ត្រីក៏**បានកើន** **៧,៩%** បើធៀបនឹងអាណត្តិទី៤ មានចំនួនតែ ២២ ៩២៤នាក់ ស្មើនឹង ២១,៨% ។ *(ព័ត៌មានលម្អិតសូមមើល ឧបសម្ព័ន្ធ ៦)*

## ៦. អ្នកបោះឆ្នោតស្ត្រី

## ៦.១. ស្ត្រីក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២១

### ក. ស្ត្រីដែលបានពិនិត្យឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត

| ចំនួនអ្នកបានពិនិត្យឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២១ | | | |
|---|---|---|---|
| ចំនួនសរុប ស្រី-ប្រុស | | ចំនួនស្ត្រី | |
| ចំនួន | % | ចំនួន | % |
| ៩ ២០៥ ៦៨១ | ៨៧,៩ | ៤ ៩០៤ ៨៣២ | ៥៣,៣ |

*(សូមមើលព័ត៌មានលម្អិតនៅក្នុងឧបសម្ព័ន្ធ ៧)*

យោងតាមលទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ចេញផ្សាយដោយគ.ជ.ប នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២ ស្ត្រីបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតទូទាំងប្រទេសមានចំនួន **៥៣,៣%** ស្មើនឹង **៤ ៩០៤ ៨៣២នាក់** នៃចំនួនប្រុស-ស្រីសរុប ៩ ២០៥ ៦៨១នាក់ ។ ដោយឡែកក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន ១០ ឃុំ សង្កាត់ ស្ត្រីបានចុះឈ្មោះថ្មីមានចំនួន ៧ ០២០នាក់ (៥៣,១%)នៃចំនួនសរុបប្រុស-ស្រី១៣.២១២នាក់ ក្នុងនោះមានស្ត្រីយៃក្មេងចំនួន ៣០៧នាក់ (៤,៤%)។ អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានជួបសម្ភាសន៍បែបសំណេះសំណាលជាមួយនឹងស្ត្រីដែលបានពិនិត្យបញ្ជីឈ្មោះ និងបានចុះឈ្មោះបោះឆ្នោត ចំនួន ៦០នាក់ ដោយទទួលបានហេតុផលមួយចំនួន[10] ៖

| **អំពី «ភាពងាយស្រួល» ក្នុងឃុំ សង្កាត់** | |
|---|---|
| **ការពិនិត្យបញ្ជីឈ្មោះ** | **ការចុះឈ្មោះបោះឆ្នោត** |
| ងាយស្រួលក្នុងការពិនិត្យឈ្មោះនៅតាមមូលដ្ឋានរបស់ខ្លួន ព្រោះនៅជិត បំផុត ដោយមានឯកសារភ្ជាប់ជាមួយ និងងាយស្រួលក្នុងការធ្វើដំណើរ ។ | ក.ច.បចុះដល់ភូមិផ្ទាល់ |
| ក.ច.បរៀបចំបានល្អ(រៀបចំតារាងឈ្មោះនិងក្តារខៀន) | ក.ច.ប មានការលើកទឹកចិត្តអ្នកមកចុះឈ្មោះ និងប្រើពាក្យសំដីគួរជាទីគោរព |
| ក.ច.បចាំជួយពិនិត្យ និងណែនាំជូនប្រជាពលរដ្ឋរាល់ចំណុចណាមួយដែលប្រជាពលរដ្ឋមិនយល់ ។ | ក្រុមប្រឹក្សាឃុំ សង្កាត់បានចេញឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះជូនប្រជាពលរដ្ឋដោយគ្មានការរើសអើង ។ |

| **អំពី «ការលំបាក» ក្នុងឃុំ-សង្កាត់** | |
|---|---|
| **ការពិនិត្យបញ្ជីឈ្មោះ** | **ការចុះឈ្មោះបោះឆ្នោត** |
| ប្រជាពលរដ្ឋខ្លះមិនសូវចេះអក្សរជាកត្តាធ្វើឱ្យពួកគាត់ពិបាកក្នុងការពិនិត្យឈ្មោះរបស់ខ្លួន | ប្រជាពលរដ្ឋខ្លះខ្វះឯកសារសម្រាប់ចុះឈ្មោះ ហើយបានបោះបង់សិទ្ធិរបស់ខ្លួនមួយចំនួន បន្ទាប់ពីមន្ត្រី ក.ច.បស្នើទៅយកឯកសារដើម្បីបំពេញឯកសារបញ្ជាក់អត្តសញ្ញាណ |
| | មានការលំបាកនៅពេលថតរូប ម៉ាស៊ីនគាំងនាំឱ្យមានការចំណាយពេលរង់ចាំយូរ (ខាតពេលវេលា) |
| ប្រជាពលរដ្ឋមួយចំនួនខ្វះមធ្យោបាយសំរាប់ធ្វើដំណើរ ដើម្បីទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ | |

[10] ខុមហ្វ្រែលបានដាក់ពង្រាយអ្នកសង្កេតការណ៍ស្ត្រីក្នុងខេត្តគោលដៅ៥ ៖ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ និងខេត្តព្រះវិហារ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២១

| មូលហេតុដែលស្ត្រីទៅពិនិត្យឈ្មោះ និងទៅចុះឈ្មោះបោះឆ្នោត | |
|---|---|
| ពិនិត្យបញ្ជីឈ្មោះ | ចុះឈ្មោះបោះឆ្នោត |
| ខ្លាចខុសឈ្មោះពី អ.ខ | ព្រោះគ្រប់អាយុត្រូវចុះឈ្មោះបោះឆ្នោត |
| ខ្លាចបាត់ឈ្មោះ | បំពេញតួនាទី ភារកិច្ចជាពលរដ្ឋខ្មែរ |
| ខ្លាចមិនបានបោះឆ្នោត | |
| ដើម្បីប្រាកដថាមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត | |
| ដើម្បីមានសិទ្ធិក្នុងការជ្រើសរើសតំណាងល្អដើម្បីបំរើដល់សង្គមជាតិយើងឱ្យកាន់តែមានការរីកចម្រើន និងមានសន្តិភាព សណ្តាប់ធ្នាប់ល្អ(ជ្រើសរើសគណបក្ស ដែលខ្លួនស្រលាញ់ពេញចិត្ត ហើយមើលឃើញថាគាត់អាចដឹកនាំឃុំ សង្កាត់បានល្អ) ។ | |

## ខ. ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត

ដោយផ្អែកទៅលើលទ្ធផលជាក់ស្តែង ស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោតពិតជាពិបាករកមកសម្ភាសន៍ពីព្រោះឃុំ សង្កាត់ខ្លះស្ត្រីបានទៅចុះឈ្មោះស្ទើរតែទាំងស្រុង និងឃុំ សង្កាត់ខ្លះប្រជាពលរដ្ឋស្ត្រីមួយចំនួនបានចំណាកស្រុកទៅក្រៅប្រទេសដោយមិនបានវិលត្រឡប់មកវិញ ។ ទោះជាយ៉ាងនេះក្តី អ្នកសង្កេតការណ៍ស្ត្រីខុមហ្វ្រែលបានខិតខំស្វែងរក និងជួប**សម្ភាសន៍បែបសំណេះសំណាល**ជាមួយនឹងស្ត្រីដែលមិនបានចុះឈ្មោះបោះឆ្នោត ចំនួន **១៥នាក់** ដែលជាទូទៅការមិនបានចុះឈ្មោះបោះឆ្នោត គឺដោយសារមូលហេតុមួយចំនួន ៖

| មូលហេតុដែលស្ត្រីមួយចំនួនមិនបានចុះឈ្មោះបោះឆ្នោត |
|---|
| គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ [ទៅធ្វើរួចហើយ តែមិនទាន់បានទទួល(ប្រើពេលយូរ)] |
| បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនដំណឹងទៅសមត្ថកិច្ច តែមិនធ្វើឱ្យ |
| អាយុមិនទាន់គ្រប់ |
| មិនចង់ទៅចុះឈ្មោះបោះឆ្នោត អស់ជំនឿគ្មានការរីកចំរើនអ្វីសោះក្នុងឃុំរបស់ខ្លួន |
| អត់មានឯកសារ |
| មានបញ្ហាឯកសារ |
| មិនបានដឹងព័ត៌មានអំពីការចុះឈ្មោះ |
| ពេលមន្ត្រីក.ច.បចុះមកភូមិ ចំពេលគាត់ទៅធ្វើការងារឆ្ងាយ |
| មិនបានដឹងព័ត៌មានចុះឈ្មោះព្រោះនៅខាងប្តី ហើយមានផ្ទៃពោះផង |

## គ. ចំណាប់អារម្មណ៍ និងការយល់ឃើញផ្ទាល់របស់អ្នកសង្កេតការណ៍ស្ត្រីខុមប្រែល

| ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ | | |
|---|---|---|
| **ទិដ្ឋភាពរួម** | **ចំណុចខ្លាំង** | **ចំណុចខ្សោយ** |
| មន្ត្រីក.ច.ប ស្មៀន មេភូមិសហការគ្នាបានល្អ ខិតខំតស៊ូគ្រប់ពេលវេលានិងបំពេញតួនាទីបានល្អ នៅរង់ចាំប្រជាពលរដ្ឋដែលមកពីស្រែចំការរហូតដល់ម៉ោង ៦ល្ងាច និងចេះជួយសម្របសម្រួល និងផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងអ្នកសង្កេតការណ៍។ រីឯខាងក្រៅការិយាល័យចុះឈ្មោះ មានសន្តិសុខសណ្តាប់ធ្នាប់ដំណើរការល្អ ក្នុងនោះក៏មានប្រជាពលរដ្ឋមួយចំនួនមិនទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត( ឃុំក្តីដូង និងឃុំភ្នំត្បែងពីរ )។ | ក្រុមមន្ត្រីក.ច.ប និងមន្ត្រីក្រុមប្រឹក្សាឃុំ-សង្កាត់សហការគ្នាបានល្អ ពួកគាត់មានការយក ចិត្តទុកដាក់រួមទាំងធ្វើការសំណេះសំណាល និងជួយណែនាំដល់ប្រជាជនក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតថែមទាំងបានបង្កនូវភាពស្និទស្នាលទទួលស្គាល់ និងមានការយកចិត្តទុកដាក់ជាមួយអ្នកសង្កេតការណ៍ផ្តល់បទ សម្ភាសន៍ និងផ្តល់ព័ត៌មានបានលឿន។មន្ត្រីចុះឈ្មោះបោះឆ្នោតរួសរាយ និងគោរពពេលវេលាដោយបានត្រៀមជាមុនក្នុងការជួយពន្យល់ដល់ប្រជាពលរដ្ឋយ៉ាងក្បោះក្បាយពីលក្ខខណ្ឌ និងរបៀបធ្វើឯកសារ ។ ចំណែកលោកមេភូមិបានស្វះស្វែងរកអ្នកគ្រប់អាយុបោះឆ្នោតមកចុះឈ្មោះបោះឆ្នោតផងដែរ ។ | អាជ្ញាធរឃុំ សង្កាត់មិនបានផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ។ ក្រុមការងារឃុំសង្កាត់ខ្វះការអប់រំដល់ប្រជាពលរដ្ឋហើយផ្តល់ព័ត៌មានមិនច្បាស់លាស់ថែមទាំងធ្វើការយឺតម៉ោង ជាពិសេសពេលព្រឹក និងមានបញ្ហាកំហុសបច្ចេកទេស ។ ប្រជាពលរដ្ឋខ្លះខ្វះការយល់ដឹងមិនសូវចេះអក្សរពេលមកពិនិត្យបញ្ជីឈ្មោះ មានអ្នកខ្លះមិនបានយកឯកសារមកជាមួយ (ឯកសារមិនគ្រប់គ្រាន់) និងប្រជាពលរដ្ឋខ្លះ ខ្វះការយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនជាពលរដ្ឋមួយរូបរស់នៅក្នុងសង្គម។ |

## ៦.៧. ថ្ងៃបោះឆ្នោត




*ប្រភព ៖ Radio Free Asia*



**ប្រភព ៖ Khmer Times**

អ្នកមានសិទ្ធិបោះឆ្នោតជាស្ត្រីនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២១ មានចំនួន **៤ ៩០៤ ៨៣២នាក់** ស្មើនឹង **៥៣,៣%** នៃចំនួនអ្នកមានសិទ្ធិបោះឆ្នោតស្រី-ប្រុសសរុប ៩ ២០៥ ៦៨១នាក់[11] សម្រាប់ការ បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២នេះ ។ មានអ្នកបោះឆ្នោតចំនួន ៧ ១៧២ ៤៤៨នាក់ ស្មើនឹ៧៧,៩%[12]ក្នុងនោះតាមការប៉ាន់ស្មានអ្នកបោះឆ្នោតស្ត្រី **ច្រើនជាង**អ្នកបោះឆ្នោតបុរសបានបោះឆ្នោតនៅថ្ងៃបោះឆ្នោត នាថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២។ របាយការណ៍សង្កេតរបស់អ្នកសង្កេតការណ៍ស្ត្រី**ខុមហ្វ្រែល និង**BCV និង អ្នកសង្កេតការណ៍ស្ត្រី-បុរសរបស់អង្គការGADCក្នុងខេត្តគោលដៅចំនួន៧ បានរកឃើញថា[13] ក្នុងចំណោមការិយាល័យបោះឆ្នោតសរុប ចំនួន**៨៧** មាន **៧៥**ការិយាល័យបោះឆ្នោត ស្មើនឹង **៨៦,២%** ស្ត្រីបានមកបោះឆ្នោត **ច្រើនជាង** បុរសដែលមានចន្លោះចាប់ពី **៥១,១%** រហូតដល់ **៧៨%** ។




**ប្រភព ៖ ខុមហ្វ្រែល**

អ្នកមានសិទ្ធិបោះឆ្នោតចំនួន **២ ០៣៣ ២៣៣នាក់ (២២,១%)**មិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត។ ការខកខានមិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោតនេះក៏អាចមានស្ត្រីមួយចំនួនធំផងដែរ ។ ពួកគេបានជួបការលំបាក ខ្លះក្នុងការទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយសារមានមូលហេតុ និងភាពមិនប្រក្រតីមួយចំនួនដែលប៉ះពាល់ដល់សិទ្ធិអ្នកបោះឆ្នោត ជាពិសេសអ្នកបោះឆ្នោតស្ត្រី ដូចជា មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែបាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហួសសុពលភាព ឬមិនមានឯកសារគ្រប់គ្រាន់ ។ ឈ្មោះ និងទិន្នន័យរបស់ខ្លួនមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត ។ មិនអាចរកឈ្មោះរបស់ពួកគាត់ឃើញនៅក្នុងបញ្ជីបោះឆ្នោត និងបានជួបបញ្ហាជាយថាហេតុមួយចំនួន ។

[11] លទ្ធផលផ្លូវការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ២០២១ ចេញផ្សាយដោយគជប នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២២

[12] ចំនួនអ្នកបានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ ចេញផ្សាយដោយគជប នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២

[13] របាយការណ៍សង្កេតរបស់ខុមហ្វ្រែល BCV and GADC ស្ដីពី « ការចូលរួមនយោបាយរបស់ស្ត្រីក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ក្នុងខេត្តគោលដៅ ៧ (ខេត្តកំពង់ធំ កំពង់ចាម កំពង់ឆ្នាំង តាកែវ ព្រះវិហារ ពោធិ៍សាត់ និងខេត្តព្រៃវែង)

យោងតាមរបាយការណ៍សង្កេតស្ត្រី បានរកឃើញទៀតថា នៅថ្ងៃបោះឆ្នោតមានបញ្ហា និងភាពមិនប្រក្រតីកើតឡើងចំពោះអ្នកបោះឆ្នោតជាស្ត្រី ចំនួន ***៩៥ករណី*** នៅក្នុង**២៨ការិយាល័យបោះឆ្នោត** ដូចជា ៖ (១) អ្នកបោះឆ្នោតជាស្ត្រីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ប៉ុន្តែបាត់/គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហួសសុពលភាព ឬមិនមានឯកសារគ្រប់គ្រាន់ ។ (២)ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត ។ (៣) អ្នកបោះឆ្នោតជាស្ត្រីមួយចំនួនមិនអាចរកឈ្មោះរបស់ពួកគាត់ឃើញនៅក្នុងបញ្ជីបោះឆ្នោត ដោយសារតែពួកគាត់មិនបានទទួលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ឬមិនដឹងពីការផ្លាស់ប្តូរលេខកូដការិយាល័យបោះឆ្នោត ។ (៤)អ្នកបោះឆ្នោតជាស្ត្រីមួយចំនួនជួបបញ្ហាជាយថាហេតុ ដូចជា ក្នុងគ្រួសារមានអ្នកជំងឺត្រូវទៅពេទ្យបន្ទាន់ និងមានបញ្ហាសុខភាព ។ (៥) អាជ្ញាធរ ឬ/និង សកម្មជនគណបក្សនយោបាយឈរនៅមុខការិយាល័យបោះឆ្នោត ហើយមេភូមិបានសួរអ្នកបោះឆ្នោតថា «បោះឈ្មោះឱ្យអ្នកណា» និងមេភូមិប្រធានក្រុមបានកៀរគរ និងដឹកប្រជាជនតាមផ្ទះមកបោះឆ្នោត ។

ការស្ទង់មតិរហ័ស (Rapid Survey) ស្តីពីការចូលរួមនយោបាយរបស់ស្ត្រីនៅក្នុងខេត្តគោលដៅទាំង៧ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ក្រោយថ្ងៃបោះឆ្នោតមួយថ្ងៃទៅលើ ***«ស្ត្រីបានបោះឆ្នោតឬមានទឹកខ្មៅនៅម្រាមដៃនិងស្ត្រីមិនបានបោះឆ្នោត ឬមិនមានទឹកខ្មៅនៅម្រាមដៃ»***បានបង្ហាញឱ្យឃើញថា ក្នុងចំណោមស្ត្រី សរុប **១១៩នាក់** ដែលបានសម្ភាសន៍ មាន **៦៤%បានបោះឆ្នោត** ដោយបានលើកពីមូលហេតុដែលខ្លួន បានចេញទៅបោះឆ្នោត និង**៣៦%មិនបានបោះឆ្នោត** ដោយបានលើកឡើងពីបញ្ហារបស់ខ្លួនដែលមិនអាចចេញទៅបោះឆ្នោតបាន ។

### ៦៤% នៃស្ត្រីដែលបានទៅបោះឆ្នោត បានលើកឡើងថាពួកគាត់ចង់ទៅបោះឆ្នោត ដោយសារ ៖

| មូលហេតុ |
|---|
| ពួកគាត់ចង់ប្រើប្រាស់សិទ្ធិក្នុងការបោះឆ្នោត |
| ពួកគាត់គាំទ្រគណបក្សដែលគាត់ពេញចិត្ត |
| ព្រោះគ្រប់ៗគ្នាគេទៅបោះឆ្នោត |
| ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ |
| សង្ឃឹមថានឹងទទួលបានតំណាងស្ត្រីដែលជាមេដឹកនាំល្អ និងមានការគិតគូដល់បញ្ហាស្ត្រី និងកុមារ ជាពិសេសត្រូវធ្វើឱ្យប្រព័ន្ធសិក្សាអប់រំមានលក្ខណៈកាន់តែទូលំទូលាយ និងធ្វើឱ្យគោលនយោបាយសេដ្ឋកិច្ចមានលក្ខណៈល្អប្រសើរជាងមុន។ |
| សង្ឃឹមថានឹងមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំ សង្កាត់របស់ខ្លួន |

***៧៦% នៃស្ត្រីដែល<u>មិនបានទៅបោះឆ្នោត</u> បានលើកឡើងថា ពួកគាត់មិនចង់/មិនបានទៅបោះឆ្នោត ដោយសារ ៖***

| មូលហេតុ |
|---|
| មិនមានពេលទៅបោះឆ្នោត |
| មិនយល់ពីនយោបាយ |
| មិនគិត ឬមិនយកចិត្តទុកដាក់លើបញ្ហានយោបាយ |
| រកឈ្មោះមិនឃើញ |
| ឈ្មោះ និងទិន្នន័យមិនត្រឹមត្រូវ (ក្នុងបញ្ជីឈ្មោះបោះឆ្នោត) |
| បញ្ហាសុខភាព |
| បាត់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ |
| ភ្លេចអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅកន្លែងធ្វើការ |
| ត្រូវទៅមើលថែឪពុកនៅមន្ទីរពេទ្យ |

# III. សេចក្តីសន្និដ្ឋាន និងសង្ខេប

កម្ពុជានៅបន្តបញ្ហាវិសមភាពនៃតំណាងរវាងបុរស និងស្ត្រីនៅក្នុងវិស័យនយោបាយ ប៉ុន្តែស្ត្រីបានចូលរួមក្នុងកិច្ចការនយោបាយ ការបោះឆ្នោតយ៉ាងសកម្មទាំងសម្លេង និងសកម្មភាពពីមួយអាណត្តិទៅមួយអាណត្តិ។ ជាក់ស្តែង ភាគរយសរុបនៃស្ត្រី និងបុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មានគម្លាតគ្នាឆ្ងាយ ក្នុងនោះស្ត្រីជាប់ឆ្នោត **២២%** និងបុរសជាប់ឆ្នោត **៧៨%** ខណៈដែលសិទ្ធិ អំណាចផ្លូវការពេញលេញរបស់ស្ត្រីក្នុងការបំពេញតួនាទីរបស់ខ្លួននៅមានការប្រឈមនឹងការរើសអើង និងនៅមានកម្រិត ។ នេះយើងមិនទាន់វិភាគទៅដល់ភាពចម្រុះផ្សេងទៀតរបស់ស្ត្រីដែលមានពិការភាព ជនជាតិដើមភាគតិច អ្នកស្រលាញ់ភេទដូចគ្នាជាដើមផង ដោយសារភាពមិនគ្រប់ជ្រុងជ្រោយនៃទិន្នន័យ ។

ការចូលរួមនយោបាយរបស់ស្ត្រីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះត្រូវបានរកឃើញថា នៅតែមានភាពប្រឈមច្រើនរាប់ចាប់ពីការទទួលបានឱកាសក្នុងការឈរឈ្មោះជាបេក្ខជន ការចូលរួមបោះឆ្នោត និងឱកាសឈានទៅមុខក្នុងជីវិតនយោបាយរបស់ស្ត្រីជាប់ឆ្នោត ។ ជាពិសេស បានទទួលឱកាសតិចតួចឈរឈ្មោះនៅលេខរៀងទី១នៃបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ និងមានគម្លាតគ្នាខ្លាំងរវាងបេក្ខជនស្ត្រី និងបេក្ខជនបុរស ស្ត្រីជាប់ឆ្នោត និងបុរសជាប់ឆ្នោត ហើយគម្លាតកាន់តែខ្លាំងរវាង មេឃុំ ចៅសង្កាត់ស្ត្រី និងមេឃុំ ចៅសង្កាត់បុរសដែលជាអ្នកដើរតួនាទីសំខាន់ជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ផង និងជាអ្នកដឹកនាំ ចាត់ចែងអភិវឌ្ឍន៍នៅទូទាំង ១៦៥២ ឃុំ សង្កាត់ផង ។ បញ្ហាទាំងនេះកើតឡើងដោយសារ ប្រទេសកម្ពុជា**ពុំទាន់មានគោលនយោបាយសមភាពយេនឌ័រ**ដាក់លាក់ជាលាយលក្ខណ៍អក្សរនៅក្នុងគណបក្សនយោបាយដែលជាវិធានការពិសេស និងខ្វះ**នូវមាត្រាមួយចំនួនដែលឆ្លើយតបនឹងតម្រូវការយេនឌ័រនៃច្បាប់បោះឆ្នោត**ដើម្បីគាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រី-បុរសដែលមានភាពចម្រុះចូលរួមស្មើគ្នាលើតួនាទីសម្រេចចិត្តក្នុងវិស័យនយោបាយស្របតាម អនុសញ្ញាស៊ីដ (CEDAW) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព*(SDG)* ដែលកម្ពុជាបានទទួលយក ។ កង្វះឆន្ទៈនយោបាយរបស់គណបក្ស និងការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំក្នុងការជម្រុញឱ្យមានសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ។ បន្ថែមលើនេះទៀត សកម្មជនគណបក្សនយោបាយជាស្ត្រី និងអ្នកនយោបាយស្ត្រីនៅតែប្រឈមនឹង**ការរើសអើង** និង**ហិង្សាគ្រប់ទម្រង់**ដែលជាឧបសគ្គរាំងពួកគេក្នុងការចូលរួមក្នុងសកម្មភាពនយោបាយ និងការទទួលបាននូវយុត្តិធម៌យេនឌ័រ និងផលប្រយោជន៍ពីការចូលរួមក្នុងវិស័យនយោបាយ ។ បទដ្ឋានវប្បធម៌ និងសង្គមមួយចំនួនដែលមានផ្នត់គំនិតអវិជ្ជមានក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី គឺជាឫសគល់បញ្ហាបង្កជារនាំងរាំងដល់ការចូលរួម របស់អ្នកនយោបាយស្ត្រីប្រកបដោយគុណភាពនិងប្រសិទ្ធភាព ។

គណបក្សនយោបាយទាំង១៧ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅតែបង្ហាញឱ្យឃើញថា ការងារលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី

នៅមានកំរិតនៅឡើយ តាមរយៈលទ្ធផលនៃការឈរឈ្មោះជាបេក្ខជន ជាពិសេសការឈរឈ្មោះជាបេក្ខជនរបស់ស្ត្រីនៅលំដាប់លេខរៀងទី១ដែលមានឱកាសច្រើនក្នុងការក្លាយជាអ្នកដឹកនាំនៅតាមឃុំ សង្កាត់ (ជាមេឃុំ ចៅសង្កាត់) ។ ជាក់ស្តែង ចំនួននិងភាគរយសរុបនៃបេក្ខជនស្ត្រី និងបេក្ខជនបុរសឈរឈ្មោះនៅ **លេខរៀងទី១ មានគម្លាតគ្នាខ្លាំង គឺ** បេក្ខជនស្ត្រី មានតែ **១២%** ខណៈដែលបេក្ខជនបុរសមានច្រើនលើសលុប **៨៨%** ។

គណបក្សពីរដែលទទួលបានការគាំទ្រពីអ្នកបោះឆ្នោត និងទទួលបានអាសនៈច្រើនក្នុងអាណត្តិទី៥នេះ គឺ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សភ្លើងទៀន** ប៉ុន្តែ អ្នកដឹកនាំគណបក្សទាំងពីរនេះនៅខ្វះការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួន និងគោលនយោបាយរួមទាំងថវិកាដែលបម្រុងទុកក្នុងការបង្កើនសមភាពយេនឌ័រក្នុងវិស័យនយោបាយ និងតួនាទីសម្រេចចិត្ត ដោយបានដាក់បេក្ខជនស្ត្រីឈរឈ្មោះមានភាគរយ**តិច ហើយបេក្ខជនស្ត្រីភាគច្រើនឈរឈ្មោះនៅលេខរៀងខាងក្រោម**នៅក្នុងបញ្ជីឈរឈ្មោះគណបក្សរបស់ខ្លួន សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នេះ ។

**ចំនួននិងភាគរយសរុបនៃស្ត្រីជាប់ឆ្នោត និងបុរសជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៃគណបក្សនយោបាយទាំងបីមានគម្លាតគ្នាខ្លាំងរវាងភេទ** គឺ គណបក្សប្រជាជនកម្ពុជា មានស្ត្រីជាប់ឆ្នោតចំនួន **២ ៣៦២នាក់ (២៥,២%)** និងបុរសជាប់ឆ្នោតចំនួន **៧ ០១៤នាក់ (៧៤,៨%)** ខណៈដែល គណបក្សភ្លើងទៀន មានស្ត្រីជាប់ឆ្នោតចំនួន **១៩៩នាក់ (៩%)** និងបុរសជាប់ឆ្នោតដ៏ច្រើនលើសលុប ចំនួន **១ ៩៩៩នាក់ (៩១%)** ។ ចំណែកឯ គណបក្សប្រជាធិបតេយ្យមូលដ្ឋាន មានស្ត្រីជាប់ឆ្នោតចំនួន **១នាក់ (១៦,៧%)** ខណៈដែលបុរសជាប់ឆ្នោតចំនួន **៥នាក់ (៨៣,៣%)** ។

**គណបក្សនយោបាយប្រមាណ ៣០%** ក្នុងចំណោមគណបក្សនយោបាយ១៧ បានគិតគូរក្នុងការដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន សម្រាប់អាណត្តិទី៥ ។

អ្នកបោះឆ្នោតស្ត្រី **ច្រើនជាង** អ្នកបោះឆ្នោតបុរសបានចេញទៅបោះឆ្នោត នៅថ្ងៃបោះឆ្នោតថ្ងៃអាទិត្យ ទី៥ ខែមិថុនា ឆ្នាំ២០២២ ។ អ្នកបោះឆ្នោតស្ត្រីបានបោះឆ្នោតតាមការិយាល័យបោះឆ្នោតចន្លោះពី **៥១,១%** ដល់ **៧៨%** នៅក្នុង**៧៥**ការិយាល័យបោះឆ្នោតនៃតំបន់គោលដៅរបស់ខុមហ្វ្រែល ហ្គេតស៊ី និងប៊ីស៊ីវី។

**ពុំមានស្ត្រីសោះ**ជាអ្នកដឹកនាំនៅថ្នាក់ជាតិជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ក្នុងចំណោមសមាសភាពទាំង**៩រូប** និងជាអគ្គលេខាធិការនិងអគ្គលេខាធិការរងទាំង **៥រូប** ។ ផ្ទុយទៅវិញ **ស្ត្រីកាន់តែច្រើនជិត ៥០%** ចូលរួមចាត់ចែងការបោះឆ្នោតនៅថ្នាក់ទាបជាមន្ត្រីគកបនិងគករ ។ **៥៦%**នៃស្ត្រីជាមន្ត្រីការិយាល័យបោះឆ្នោតមានតួនាទីជា**សមាជិក** ខណៈដែលតួនាទីជា**ប្រធាន**មាន**តិចតួច**បំផុត **៦%** នៅក្នុង **៩៧**ការិយាល័យបោះឆ្នោត ។

ស្ត្រី និងបុរសខ្មែរត្រូវបានធានាយ៉ាងពេញលេញ និងស្មើភាពគ្នាដោយរដ្ឋធម្មនុញ្ញកម្ពុជាស្តីពី ការចូលរួម និងផលប្រយោជន៍នយោបាយរបស់ពួកគេ។ ទោះយ៉ាងណា លក្ខណៈងាយស្រួលសម្រាប់ស្ត្រី និងបរិយាកាសអំណោយផល (women friendly and enabling environment) គោលនយោបាយ ច្បាប់បោះឆ្នោត និងមាត្រដ្ឋាននៃប្រតិបត្តិការ មិនទាន់បានឆ្លើយតបជាក់ស្តែងចំពោះស្ថានភាពនៃការចូលរួមរបស់ស្ត្រីក្នុងឆាក

នយោបាយទេ។ គម្លាតនៃគោលនយោបាយ និងច្បាប់បោះឆ្នោតមិនឆ្លើយតបនឹងយេនឌ័រ មាត្រដ្ឋាននៃប្រតិបត្តិការ និងការវិនិយោគ បាន**ពង្រឹងវិសមភាព**នៃភាពជាតំណាង និងការចូលរួមរបស់ស្ត្រី។ ដូច្នេះ មានគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្ស និងច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ ហើយត្រូវអនុវត្តបានល្អនឹងក្លាយជាឧបករណ៍ដ៏សំខាន់ និងមានប្រសិទ្ធភាពសម្រាប់ស្ត្រីក្នុងការទាមទារសិទ្ធិរបស់ពួកគេ និងចាប់យកឱកាសស្មើភាពគ្នាជាបេក្ខជនឈរឈ្មោះ និងជាប់ឆ្នោត ។ បន្ថែមពីនេះ ការប្តេជ្ញាចិត្តខ្ពស់របស់អ្នកដឹកនាំ និងឆន្ទៈនយោបាយក្នុងការគាំទ្រ គឺជាកត្តាចាំបាច់ដែលជម្រុញឱ្យការងារនេះទទួលបានជោគជ័យ ។

## IV. អនុសាសន៍

ដើម្បីបង្កើនសមភាពយេនឌ័រ និងផ្តល់អំណាចនយោបាយដល់ស្ត្រី វិធានការខាងក្រោមគួរត្រូវបានដោះស្រាយ៖

### ១. រដ្ឋសភា និងព្រឹទ្ធសភា (National Assembly and Senate)

ជានាបង្កើតច្បាប់បោះឆ្នោតឆ្លើយតបនឹងយេនឌ័រ ទាំងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាវិធានការពិសេសដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមដោយស្មើភាពនៅក្នុងវិស័យ នយោបាយ និងការអនុវត្តច្បាប់នេះបានល្អ ។ វិធានការពិសេសនេះ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយដែលអាចជម្រុញលើកទឹកចិត្តគ្រប់គណបក្សនយោបាយដាក់បេក្ខភាពស្ត្រីច្រើននៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស ។ ការលើកទឹកចិត្តដើម្បីអនុវត្តរបស់គណបក្សនយោបាយនេះ គឺត្រូវបង្កើតក្នុងក្របខណ្ឌច្បាប់ គឺសំដៅដល់ការធ្វើវិសោធនកម្មច្បាប់សម្រាប់ការបោះឆ្នោត ។ វិសោធនកម្មច្បាប់នេះ កែលម្អបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឲ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើ ដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ ។ ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដូចជាច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ **ជំពូកទី៤ មាត្រា២៧ និងមាត្រា២៨** « ***បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលនីមួយៗ ត្រូវមានបេក្ខជនស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នាតាមលំដាប់លេខរៀងពីលើដល់ក្រោម*** » និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ **ជំពូកទី៦ មាត្រា៣៩** « ***បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងឆ្លាស់គ្នារវាងស្ត្រី និងបុរសពីលើដល់ក្រោម*** » ។

### ២. គណបក្សនយោបាយ (Political Party)

ជានាបង្កើតគោលនយោបាយសមភាពយេនឌ័រនៅក្នុងគណបក្សដោយគណបក្សនយោបាយ ហើយគោលនយោបាយនេះត្រូវអនុវត្តឱ្យបានល្អ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីដោយស្មើភាព និងគ្មានការរើសអើងនៅក្នុងគណបក្សនយោបាយរបស់ខ្លួន ដូចជា ស្ត្រីក្នុងដំណើរការបង្កើតគោលនយោបាយ អ្នកធ្វើសេចក្តីសម្រេចចិត្ត និងតួនាទីជាអ្នកដឹកនាំ ស្ត្រីជាបេក្ខជនឈរឈ្មោះបោះឆ្នោត និងតំណាងស្ត្រីជាប់ឆ្នោត ។ គោលនយោបាយសមភាពយេនឌ័រ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការជំរុញលើកទឹកចិត្តឱ្យគណបក្សនយោបាយទាំងអស់ដាក់បេក្ខភាពស្ត្រីឱ្យបានច្រើននៅក្នុងបញ្ជីបេក្ខជនរបស់គណបក្ស ដោយប្រើប្រព័ន្ធឆ្លាស់គ្នាតាមលំដាប់លេខរៀងពី លើ ដល់ ក្រោម រវាងបេក្ខជនស្ត្រី និងបេក្ខជនបុរស និងបង្កើនសមភាពយេនឌ័រនៅគ្រប់ជាន់ថ្នាក់នៅក្នុងគណបក្សនយោបាយ ។

## ៣. ស្ថាប័នរដ្ឋ និងស្ថាប័នសាធារណៈ (State and Public Institutions)

- រាជរដ្ឋាភិបាលកម្ពុជា (ក្រសួងពាក់ព័ន្ធ) គួរផ្ដល់ការគាំទ្រគ្រប់បែបយ៉ាងដូចជា ថវិកា ធនធាននានា និងធនធានមនុស្សដល់អ្នកដឹកនាំស្ត្រី និងស្ត្រីជាប់ឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើនប្រសិទ្ធភាព និងគុណភាពនៃការចូលរួមនយោបាយ ការងារ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ។
- រាជរដ្ឋាភិបាលកម្ពុជាត្រូវពង្រឹងការគោរពសិទ្ធិនយោបាយរបស់ស្ត្រី និងធានាឱ្យបានក្នុងការអនុវត្តសិទ្ធិនេះ ដោយបង្កលក្ខណៈងាយស្រួលដល់ស្ត្រីធ្វើការជួបជជែកគ្នាអំពីកិច្ចការនយោបាយ និងកិច្ចការផ្សេងៗ ជាពិសេសសម្រាប់អ្នកនយោបាយស្ត្រីដែលមកពីគណបក្សប្រឆាំង និងគណបក្សផ្សេងទៀត ប្រយោជន៍ គាំទ្រ និងផ្ដល់ឱកាសឱ្យស្ត្រីចូលរួមកាន់តែច្រើនក្នុងកិច្ចការនយោបាយ និងថ្នាក់សម្រេចចិត្ត ស្របតាមអនុសញ្ញាស៊ី-ដរ(CEDAW)និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា(CSDG)។
- ក្រសួងមហាផ្ទៃ និងអាជ្ញាធរពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានាចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ជាពិសេសស្ត្រីទទួលបាននូវតួនាទី ភារកិច្ច និងសិទ្ធិអំណាចពេញលេញស្របតាមច្បាប់ស្តីពី «ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់» និងអនុសញ្ញាស៊ី-ដរ។ ឧទាហរណ៍ ការបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃដើម្បីត្រួតពិនិត្យលក្ខខណ្ឌការងារ និងបញ្ហាប្រឈមរបស់ពួកគេ ។

## ៤. អង្គការសង្គមស៊ីវិល វិទ្យាស្ថានអប់រំ និងការសិក្សា (CSOs, Educational Institutions and Academies)

- បង្កើនយន្តការគាំទ្រសម្រាប់អ្នកនយោបាយស្ត្រីដូចជា ការអភិវឌ្ឍសមត្ថភាព (ទំនុកចិត្តលើខ្លួនឯង និងជំនាញដែលចាំបាច់ដើម្បីចូលរួមក្នុងនយោបាយ រួមមាន ការបង្កើតយុទ្ធសាស្ត្របញ្ចុះបញ្ចូល និងយុទ្ធនាការឃោសនាប្រកបដោយប្រសិទ្ធភាព) ការផ្ដល់អំណាច និងមូនិធិនយោបាយពិសេសដល់ស្ត្រីក្នុងវិស័យនយោបាយ ។
- ប្រើប្រាស់ទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម និងប្រព័ន្ធផ្សព្វផ្សាយដើម្បីធ្វើយុទ្ធនាការអំពីសិទ្ធិស្ត្រីដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការចូលរួមក្នុងនយោបាយ និងតួនាទីជាអ្នកដឹកនាំរបស់ស្ត្រី និងបន្តពន្លឿនការលុបបំបាត់ការរើសអើង និងអំពើហិង្សាគ្រប់ទម្រង់លើស្ត្រីនៅកម្រិតសាធារណៈ នយោបាយ និងគ្រួសារ ។

## ៥. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (National Election Committee-NEC)

- បង្កើតគំនិតផ្ដួចផ្ដើម និងចូលរួមជម្រុញការធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ប្រយោជន៍ធានានូវសមភាពយេនឌ័រក្នុងការបោះឆ្នោត ជាពិសេសគាំទ្រ និងរិះរកគ្រប់មធ្យោបាយដើម្បីជួយស្ត្រីឱ្យមានឱកាសបានឈរឈ្មោះជាបេក្ខជន និងបានជាប់ឆ្នោតច្រើន ។

- ជានាបង្កើតបទបញ្ញា និងនីតិវិធីដែលឆ្លើយតបនឹងយេនឌ័ររបស់គ.ជ.បសម្រាប់ការបោះឆ្នោត ដើម្បីបង្កើនសមភាពយេនឌ័រ និងផ្តល់ឱកាសស្មើភាពដល់បេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោត ដោយបន្ថែមលក្ខខណ្ឌនៃការដាក់ពាក្យចុះឈ្មោះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ដែលតម្រូវឱ្យដាក់ឆ្លាស់គ្នារវាងបេក្ខជនស្ត្រី និងបុរសតាមលំដាប់លេខរៀងពីលើដល់ក្រោមនៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយ។

**៚៚៚✯ចប់✯៛៛៛**

# ឧបសម្ព័ន្ធ ១

## ចំនួនបេក្ខជនស្ត្រីឈរឈ្មោះតាមរាជធានី ខេត្ត
## សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

| ល.រ | រាជធានី ខេត្ត | បេក្ខជនសរុប | ស្ត្រី | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ (%) |
| 1 | បន្ទាយមានជ័យ | 4,777 | 1,518 | 31.8 |
| 2 | បាត់ដំបង | 6,137 | 2,246 | 36.6 |
| 3 | កំពង់ចាម | 6,333 | 2,016 | 31.8 |
| 4 | កំពង់ឆ្នាំង | 3,705 | 1,221 | 33.0 |
| 5 | កំពង់ស្ពឺ | 4,806 | 1,401 | 29.2 |
| 6 | កំពង់ធំ | 6,030 | 2,005 | 33.3 |
| 7 | កំពត | 3,214 | 900 | 28.0 |
| 8 | កណ្តាល | 6,611 | 2,299 | 34.8 |
| 9 | កោះកុង | 921 | 266 | 28.9 |
| 10 | ក្រចេះ | 2,734 | 941 | 34.4 |
| 11 | មណ្ឌលគិរី | 689 | 168 | 24.4 |
| 12 | រាជធានីភ្នំពេញ | 5,792 | 2,245 | 38.8 |
| 13 | ព្រះវិហារ | 2,320 | 700 | 30.2 |
| 14 | ព្រៃវែង | 6,651 | 2,161 | 32.5 |
| 15 | ពោធិ៍សាត់ | 1,747 | 524 | 30.0 |
| 16 | រតនគិរី | 1,365 | 365 | 26.7 |
| 17 | សៀមរាប | 6,113 | 2,059 | 33.7 |
| 18 | ព្រះសីហនុ | 1,623 | 458 | 28.2 |
| 19 | ស្ទឹងត្រែង | 1,183 | 306 | 25.9 |
| 20 | ស្វាយរៀង | 2,977 | 832 | 27.9 |
| 21 | តាកែវ | 4,655 | 1,272 | 27.3 |
| 22 | កែប | 231 | 81 | 35.1 |
| 23 | ប៉ៃលិន | 370 | 143 | 38.6 |
| 24 | ឧត្តរមានជ័យ | 1,331 | 496 | 37.3 |
| 25 | ត្បូងឃ្មុំ | 3,777 | 1,190 | 31.5 |
| **សរុបរួម** | | **86,092** | **27,813** | **32.3** |

# ឧបសម្ព័ន្ធ ២

## ចំនួនស្ត្រីជាប់ឆ្នោតតាមរាជធានី ខេត្ត
## សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

| ល.រ | រាជធានី ខេត្ត | ចំនួនសរុប | ស្ត្រីជាប់ឆ្នោត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ (%) |
| 1 | បន្ទាយមានជ័យ | 533 | 98 | 18.4 |
| 2 | បាត់ដំបង | 823 | 214 | 26 |
| 3 | កំពង់ចាម | 817 | 135 | 16.5 |
| 4 | កំពង់ឆ្នាំង | 427 | 102 | 23.9 |
| 5 | កំពង់ស្ពឺ | 616 | 117 | 19 |
| 6 | កំពង់ធំ | 585 | 113 | 19.3 |
| 7 | កំពត | 561 | 111 | 19.8 |
| 8 | កណ្តាល | 915 | 190 | 20.8 |
| 9 | កោះកុង | 167 | 47 | 28.1 |
| 10 | ក្រចេះ | 300 | 73 | 24.3 |
| 11 | មណ្ឌលគិរី | 107 | 27 | 25.2 |
| 12 | រាជធានីភ្នំពេញ | 899 | 244 | 27.1 |
| 13 | ព្រះវិហារ | 333 | 79 | 23.7 |
| 14 | ព្រៃវែង | 892 | 158 | 17.7 |
| 15 | ពោធិ៍សាត់ | 341 | 87 | 25.5 |
| 16 | រតនគិរី | 260 | 57 | 21.9 |
| 17 | សៀមរាប | 668 | 174 | 26 |
| 18 | ព្រះសីហនុ | 177 | 35 | 19.8 |
| 19 | ស្ទឹងត្រែង | 176 | 42 | 23.9 |
| 20 | ស្វាយរៀង | 518 | 133 | 25.7 |
| 21 | តាកែវ | 736 | 144 | 19.6 |
| 22 | កែប | 31 | 6 | 19.4 |
| 23 | ប៉ៃលិន | 52 | 16 | 30.8 |
| 24 | ឧត្តរមានជ័យ | 152 | 45 | 29.6 |
| 25 | ត្បូងឃ្មុំ | 536 | 115 | 21.5 |
| **សរុបរួម** | | **11,622** | **2,562** | **22** |

# ឧបសម្ព័ន្ធ ៣

## ចំនួនឃុំ សង្កាត់ដែលគ្មានស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥

| ល.រ | រាជធានី ខេត្ត | ស្រុក ខណ្ឌ | ឃុំ សង្កាត់ | ឃុំ សង្កាត់ ដែល គ្មានស្ត្រីជាក្រុមប្រឹក្សា | ភាគរយ |
|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 9 | 67 | 8 | 11.9 |
| 2 | បាត់ដំបង | 14 | 103 | 3 | 2.9 |
| 3 | កំពង់ចាម | 10 | 109 | 18 | 16.5 |
| 4 | កំពង់ឆ្នាំង | 8 | 71 | 9 | 12.7 |
| 5 | កំពង់ស្ពឺ | 8 | 88 | 5 | 5.7 |
| 6 | កំពង់ធំ | 9 | 81 | 7 | 8.6 |
| 7 | កំពត | 9 | 93 | 13 | 14 |
| 8 | កណ្ដាល | 11 | 127 | 2 | 1.6 |
| 9 | កោះកុង | 7 | 29 | 0 | 0 |
| 10 | ក្រចេះ | 6 | 48 | 3 | 6.3 |
| 11 | មណ្ឌលគិរី | 9 | 21 | 0 | 0 |
| 12 | រាជធានីភ្នំពេញ | 14 | 105 | 2 | 1.9 |
| 13 | ព្រះវិហារ | 8 | 51 | 2 | 3.9 |
| 14 | ព្រៃវែង | 13 | 116 | 18 | 15.5 |
| 15 | ពោធិ៍សាត់ | 7 | 49 | 2 | 4.1 |
| 16 | រតនគិរី | 9 | 50 | 3 | 6 |
| 17 | សៀមរាប | 12 | 100 | 5 | 5 |
| 18 | ព្រះសីហនុ | 5 | 29 | 8 | 27.6 |
| 19 | ស្ទឹងត្រែង | 6 | 34 | 1 | 2.9 |
| 20 | ស្វាយរៀង | 8 | 80 | 3 | 3.8 |
| 21 | តាកែវ | 10 | 100 | 12 | 12 |
| 22 | កែប | 2 | 5 | 0 | 0 |
| 23 | ប៉ៃលិន | 2 | 8 | 0 | 0 |
| 24 | ឧត្តរមានជ័យ | 5 | 24 | 0 | 0 |
| 25 | ត្បូងឃ្មុំ | 7 | 64 | 2 | 3.1 |
| **សរុបរួម** | | **208** | **1,652** | **126** | **7.6** |

## ឧបសម្ព័ន្ធ ៤

## បញ្ជីឈ្មោះមេឃុំ ចៅសង្កាត់ស្ត្រី ១៧៣នាក់ អាណត្តិទី៥

| ល.រ | ឈ្មោះ | ឆ្នាំ | អាយុ | ឃុំ សង្កាត់ | ក្រុង ស្រុក ខណ្ឌ | រាជធានី ខេត្ត | ឃុំជាប់ស្រយាល | ជនជាតិដើមភាគតិច | គណបក្សនយោបាយ | ក្រុមប្រឹក្សាចាស់/ថ្មី |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ជិម សៅឌី | ១៩៧២ | ៥០ឆ្នាំ (ស្ត្រីវ័យចំណាស់) | ឫស្សីក្រោក | មង្គលបូរី | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |
| ២ | ស្វាត់ ចាន់ថុន | ១៩៩០ | ៣២ឆ្នាំ (ស្ត្រីវ័យក្មេង) | ភ្នំដី | ភ្នំស្រុក | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣ | ធូ ណាគ្រី | ១៩៤៦ | ៧៦ឆ្នាំ (ស្ត្រីវ័យចំណាស់) | អូរអំបិល | សិរិសោភ័ណ | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤ | ឆាត សុជា | ១៩៨២ | ៤០ឆ្នាំ (ស្ត្រីវ័យក្មេង) | ព្រះពន្លា | សិរិសោភ័ណ | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៥ | គឹម ពៅ | ១៩៥៩ | ៦៣ឆ្នាំ (ស្ត្រីវ័យចំណាស់) | អូរស្រទៀ | ម៉ាឡៃ | បន្ទាយមានជ័យ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៦ | គឹម គឹមអាន | ១៩៧៧ | ៤៥ឆ្នាំ (ស្ត្រីវ័យចំណាស់) | ស្ទឹង | បាណន់ | បាត់ដំបង | | | ប្រជាជនកម្ពុជា | ចាស់ |
| ៧ | ង៉ាន ម៉ៅ | ១៩៨៤ | ៣៨ឆ្នាំ (ស្ត្រីវ័យក្មេង) | អំពិលប្រាំដើម | បវេល | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៨ | សឿង វណ្ណា | ១៩៧៨ | ៤៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | ព្រែកហ្លួង | ឯកភ្នំ | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៩ | លាវ មុំ | ១៩៩១ | ៣១ឆ្នាំ (ស្ត្រីវ័យក្មេង) | ព្រៃស្វាយ | មោងឫស្សី | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១០ | សិទ្ធ សុខា | ១៩៨១ | ៤១ឆ្នាំ (ស្ត្រីវ័យចំណាស់) | ព្រៃតូច | មោងឫស្សី | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១១ | សឿម យ៉ាប់ | ១៩៦៣ | ៥៩ឆ្នាំ (ស្ត្រីវ័យចំណាស់) | តាប៉ុន | សង្កែ | បាត់ដំបង | | | ប្រជាជនកម្ពុជា | ចាស់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១២ | ស៊ឹម ពៅ | ១៩៦២ | ៦០ឆ្នាំ (ស្ត្រីវ័យចំណាស់) | រកា | សង្កែ | បាត់ដំបង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១៣ | សួន ជាតិ | ១៩៥២ | ៧០ឆ្នាំ (ស្ត្រីវ័យចំណាស់) | តាសាញ | សំឡូត | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៤ | អ៊ុច ធឿន | ១៩៥៣ | ៦៩ឆ្នាំ ស្ត្រីវ័យចំណាស់) | សន្តិភាព | សំពៅលូន | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៥ | យុន ភន | ១៩៥២ | ៧០ឆ្នាំ (ស្ត្រីវ័យចំណាស់) | តាស្ដា | សំពៅលូន | បាត់ដំបង | | | ប្រជាជនកម្ពុជា | ចាស់ |
| ១៦ | រី ហេង | ១៩៦១ | ៦១ឆ្នាំ (ស្ត្រីវ័យចំណាស់) | ត្រាង | កំរៀង | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៧ | ជួន សុផល | ១៩៥៨ | ៦៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | តាសែន | កំរៀង | បាត់ដំបង | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៨ | ហៀង សុផល | ១៩៦២ | ៦០ឆ្នាំ (ស្ត្រីវ័យចំណាស់) | មេព្រីង | បាធាយ | កំពង់ចាម | | | ប្រជាជនកម្ពុជា | ថ្មី |
| ១៩ | ញ៉ឹក ស្រីអូន | ១៩៧០ | ៥២ឆ្នាំ (ស្ត្រីវ័យចំណាស់) | សំពងជ័យ | ជើងព្រៃ | កំពង់ចាម | | | ប្រជាជនកម្ពុជា | ថ្មី |
| ២០ | យាង ស៊ីផាន | ១៩៥៩ | ៦៣ឆ្នាំ (ស្ត្រីវ័យចំណាស់) | សំបួរមាស | កំពង់ចាម | កំពង់ចាម | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២១ | អ៊ា ចាន់ថុល | ១៩៦២ | ៦០ឆ្នាំ (ស្ត្រីវ័យចំណាស់) | កៀនជ្រៃ | កំពង់សៀម | កំពង់ចាម | | | ប្រជាជនកម្ពុជា | ថ្មី |
| ២២ | គង់ សៀកអេង | ១៩៧៥ | ៤៧ឆ្នាំ (ស្ត្រីវ័យចំណាស់) | សូរគង | កងមាស | កំពង់ចាម | | | ប្រជាជនកម្ពុជា | ថ្មី |
| ២៣ | ស៊ុន ចន្ថា | ១៩៥០ | ៧២ឆ្នាំ (ស្ត្រីវ័យចំណាស់) | កោះសូទិន | កោះសូទិន | កំពង់ចាម | | | ប្រជាជនកម្ពុជា | ចាស់ |
| ២៤ | នុត សៅ | ១៩៨០ | ៤២ឆ្នាំ (ស្ត្រីវ័យចំណាស់) | ត្រពាំងចាន់ | បរិបូណ៌ | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ២៥ | អ៊ុង គឹមអៀន | ១៩៨៤ | ៣៨ឆ្នាំ (ស្ត្រីវ័យក្មេង) | ព្រៃគ្រី | ជលគីរី | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ២៦ | ភួន ឈុយអេង | ១៩៤៣ | ៧៩ឆ្នាំ (ស្ត្រីវ័យចំណាស់) | ផ្សារឆ្នាំង | កំពង់ឆ្នាំង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ២៧ | កែវ សុផាត | ១៩៥៧ | ៦៥ឆ្នាំ (ស្ត្រីវ័យចំណាស់) | កំពង់ឆ្នាំង | កំពង់ឆ្នាំង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ២៨ | គុយ ចន្ទី | ១៩៦០ | ៦២ឆ្នាំ (ស្ត្រីវ័យចំណាស់) | កំពង់ហៅ | កំពង់លែង | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ២៩ | ទេព យ៉ារ៉េម | ១៩៥៨ | ៦៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | ពានី | កំពង់ត្រឡាច | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣០ | ស្វាយ ស៊ីម | ១៩៥៧ | ៦៥ឆ្នាំ (ស្ត្រីវ័យចំណាស់) | តាជេស | កំពង់ត្រឡាច | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣១ | ថោង ហុង | ១៩៤៦ | ៧៦ឆ្នាំ (ស្ត្រីវ័យចំណាស់) | ព្រៃមូល | រលាប្អៀរ | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ៣២ | ផាត់ សារឹន | ១៩៨៤ | ៣៨ឆ្នាំ (ស្ត្រីវ័យក្មេង) | ខ្នាឆ្មារ | សាមគ្គីមានជ័យ | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣៣ | ប៉ែន សោភា | ១៩៨០ | ៤២ឆ្នាំ (ស្ត្រីវ័យចំណាស់) | ស្វាយជុក | សាមគ្គីមានជ័យ | កំពង់ឆ្នាំង | ✓ | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៤ | ហែម គៀន | ១៩៥៨ | ៦៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | ជ្រៀប | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៥ | ឈិន សារី | ១៩៨១ | ៤១ឆ្នាំ (ស្ត្រីវ័យចំណាស់) | ចោងម៉ោង | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |
| ៣៦ | ស៊ឹម រ៉ុន | ១៩៦៥ | ៥៧ឆ្នាំ (ស្ត្រីវ័យចំណាស់) | ក្បាលទឹក | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៧ | ភឿក ហឹង | ១៩៦៦ | ៥៦ឆ្នាំ (ស្ត្រីវ័យចំណាស់) | ខ្លងពពក | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ចាស់ |
| ៣៨ | កែវ យ៉ាន | ១៩៧៨ | ៤៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | ក្រាំងស្គារ | ទឹកផុស | កំពង់ឆ្នាំង | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៣៩ | ព្រុំ សុខា | ១៩៨៣ | ៣៩ឆ្នាំ (ស្ត្រីវ័យក្មេង) | ពៅធិ៍ចំរើន | បសេដ្ឋ | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤០ | ឃួន សាមឿន | ១៩៨០ | ៤២ឆ្នាំ (ស្ត្រីវ័យចំណាស់) | គីរីវន្ត | ភ្នំស្រួច | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤១ | តាំង គឹមចេង | ១៩៥៩ | ៦៣ឆ្នាំ (ស្ត្រីវ័យចំណាស់) | អូរ | ភ្នំស្រួច | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៤២ | ព្រុំ នី | ១៩៧០ | ៥២ឆ្នាំ (ស្ត្រីវ័យចំណាស់) | កាហែង | សំរោងទង | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៤៣ | យ៉ែម សុភាព | ១៩៧៩ | ៤៣ឆ្នាំ (ស្ត្រីវ័យចំណាស់) | ខ្ទុំក្រាំង | សំរោងទង | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤៤ | យ័ញ គឹមហុន | ១៩៦៨ | ៥៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | ស្គុះ | សំរោងទង | កំពង់ស្ពឺ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤៥ | អួន យ៉ន | ១៩៦៨ | ៥៤ឆ្នាំ (ស្ត្រីវ័យចំណាស់) | បល្ល័ង្គ | បារាយណ៍ | កំពង់ធំ | | | ប្រជាជនកម្ពុជា | ថ្មី |
| ៤៦ | យឹង ហ៊ាប | ១៩៧៤ | ៥៨ឆ្នាំ (ស្ត្រីវ័យចំណាស់) | ដំរីស្លាប់ | បារាយណ៍ | កំពង់ធំ | | | ប្រជាជនកម្ពុជា | ចាស់ |
| ៤៧ | ព្រហ្ម សោភា | ១៩៧៧ | ៤៥ឆ្នាំ (ស្ត្រីវ័យចំណាស់) | ច្រនាង | តាំងគោក | កំពង់ធំ | | | ប្រជាជនកម្ពុជា | ថ្មី |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤៨ | នុត គឹមស៊ន់ | ១៩៥៣ | ៦៩ឆ្នាំ (ស្ត្រីវ័យចំណាស់) | ជ្រលង | តាំងគោក | កំពង់ធំ | | | ប្រជាជនកម្ពុជា | ថ្មី |
